# ការសំភាសន៍របស់អ្នកមីងមឿន ប៉ោង

ក៖ អ្នកដែលសំភាសន៍ឈ្មោះ ញ៉ែម សុគន្ធា     ខ៖ អ្នកដែលត្រូវគេសំភាសន៍ មឿន ប៉ោង

## ការសង្ខេបរបស់អ្នកមីងមឿន ប៉ោង

អ្នកមីងមឿន ប៉ោង ជាមនុស្សស្រីម្នាក់ដែលតស៊ូនៅក្នុងជីវិតដ៏ខ្លាំងខ្លា គាត់ជាកូនអ្នកស្រុកស្រែម្នាក់ដែលរស់នៅក្នុងទឹកដីនៃខេត្តសៀមរាប ហើយគាត់មានស្វាមីដែលជាអ្នកឡើងត្នោតហើយពួកគាត់បានរកស៊ីរបរធ្វើស្ករត្នោត។គាត់បានឆ្លងកាត់នៅក្នុងរបបសង្គ្រាមប៉ុលពតដ៏សែនលំបាកហើយឪពុកគាត់បានស្លាប់នៅក្នុងរបបនោះផងដែរ គាត់ធ្លាប់បានឃើញពួកទាហានប៉ុល ពតបាននាំមនុស្សចងហើយយកទៅសម្លាប់ផងដែរ។ហើយក៏បានទាន់នៅក្នុងរបបលន់នល់ទំលាក់គ្រាប់បែកហើយបានត្រូវក្មេងហើយស្លាប់ទៅទើរនៅចុងឈើ។

ក៖អូខេ ជាដំបូងចឹងជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកមីងដែលអោយញ៉ាមសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងនាងខ្ញុំឈ្មោះញ៉ែម សុគន្ធាជាអក្នកសំភាសន៍នៅក្នុងថ្ងៃនេះហើយការសំភាសន៍របស់ពួកយើងគឺនៅក្នុងថ្ងៃទី០៦ ខែ១០ ឆ្នាំ២០១៧ហើយការសំភាសន៍នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យនៅប្រទេសអាមេរិចឈ្មោះថា ប៊ី វ៉ាយយូហើយញ៉ាមសូមចាប់ផ្តើមសំភាសន៍អំពីជីវប្រវត្តិអ្នកមីងតែម្តង។ ចឹងអ្នកមីងសូមប្រាប់ឈ្មោះអ្នកមីងពេញទាំងត្រកូលហ៎ា!! អ្នកមីងឈ្មោះអីដែរ?

ខ៖ឈ្មោះ មឿន មាស។

ក៖មឿន មាស?

ខ៖ចា៎។

ក៖ហ្អឹងហើយ។

ខ៖នាមត្រកូលឈ្មោះមឿន មាស គេហៅញ៉ាមសព្វថ្ងៃ មឿន ប៉ោង។

ក៖ពង?

ខ៖ ប៉ោង។ ប៉េតប៉ោងយើងហ្អឹង។

ក៖មឿន ប៉ោង។

ខ៖ ចា៎មឿន ប៉ោង។

ក៖ហើយម៉េច ចឹងអ្នកមីងស្គមសឹងអីហើយហ្អឹង។

ខ៖ហ៊ើយ បើមិនសគមឯណាបើនឿយ។ក៖ចា៎។ខ៖ញ៉ាមនឿយណាស់មួយជីវិតនេះញ៉ាមនឿយតាំងពីក្មេងរហូតដល់ចាស់។

ក៖ចា៎ហ្អឹងហើយ។

ខៈចំា៎តាំងពីក្មេងមកអាដែងតាំងពីញុំមអាយុនៅទូចៗ ១២ ១៣ ជំនាន់អាពតកំព្រាដូចកព្រា ម៉ែឪទាំងអស់ចុះបើម៉ែទៅផ្សេងកូនទៅផ្សេង។

កៈចំា៎។

ខៈចំា៎យប់ឡើងបើខែរងាអីចឹងនាំគ្នាដុះធាងដូងដុះ ផ្ទះចេះដុះអុស យើដាក់ដីបានដាក់អាធូបធុងសាំងអាគរបធុងសាំងហ្នឹងដាក់បិតបានដុះភ្លើងអោយភ្លឺលើផ្ទះយប់ឡើងដេកតែ២នាក់បងប្អូនងងុយទៅ បងៗបែកអស់នៅតែ៣នាក់ទូចៗ។

កៈ។

ខៈអាប្អូនមិទាន់មិមដាច់ផងទៅទៅ ដល់ពេលប្អូនយំ នាំបងប្អូនលួងបងប្អូនមិនបាត់យំទាំងអស់គ្នាចុះយបអាជ្រោតម៉ែគេអត់អោយមកដូចថាគាត់ទៅចល័តឆ្ងាយទៅសុំអត់អោយមកណាស់ទៅក៏នាំគ្នាដេកតែ៣នាក់បងប្អូន ប៉ិនកាលណាវាក្រោឡើងវាឃ្លានមិមវា យើងអត់មានបាយហូបអត់មានបាយបញ្ចុកវាទៅវាចេះតែយំ។

កៈហ្នឹងហើយ ក្មេងមីងណោះ?

ខៈចំា៎។ចេះតែយំទៅ លួងអត់បានក៏លួងប្អូន អាគេអ្នកជិតខាងគេស្រណោះទៅគេមកជួយលួង ហើយវាមិនបាត់ទៀត ទៅដល់ពេល អូយលួងមិនបាត់ទេទៅផ្ទះប្រធានក្ពុមអោយគេជួយលួងហ៎ា ទៅផ្ទះប្រធានក្រុមគេមានបាយមានអីអោយហូបនោះ ទៅទៅដល់ទៅគេដាក់ដាំបបរបញ្ចុកវាទៅហូបរួចដេក។

កៈបានគេងទៅ។

ខៈហូបរួចដេកវាស់ព្រឹក ហូបរួចបានស្អែកឡើងគេទៅទៅប្រាប់ម៉ែទៅ គាត់មកយកទៅតែពេលមកលេងកូនអញ្ចេះទុកពាដង ទុកហ្នឹងញុំមពាដងថាអូយវេទនាណាស់។

កៈចំា៎។

ខៈអត់បានដេកទេវាយំ យន់ថ្ងៃចេះណាស់ពរប្អូនផងដើរកន្តៀតអាចម៍គោផង ចុះយើនៅកុមារនោះ!!!កៈចំា៎!!ខៈកណ្តៀតអាចម៍គោផង ពរប្អូនមួយចំហៀងដៃ។

កៈចំា៎ហ្នឹងហើយ។ចឹងអ្នកមីងមានឈ្មោះអីហៅក្រៅពីប៉ោងហ្នឹងទៀតទេ?

ខៈអត់៕

កៈអត់ទេមានតែមួយហ្នឹងហេ?

ខៈតែឈ្មោះប៉ោងរហូត នៅពីទូចម៉េចគេហៅមាសអត់ឆ្លើយទេ។កៈចំា៎។ខៈរួចរូបយើងប្រុសនោះ!!!គេហៅឈ្មោះល្អជាអត់យកទេ។

កៈហ្នឹងហើយ តែឈ្មោះក្នុងបញ្ជីជាតិម៉ងហ៎ាអ្នកមីង!!!ខៈចំា៎។កៈឈ្មោះអីគេ?បញ្ជីជាតិមាស?

ខៈអត់ទេ ណែគេហៅប៉ុន្តែញុំមអត់ដាក់ ដាក់ប៉ោងរហូត។

កៈចំា៎នៅក្នុងបញ្ជីជាតិសព្វថ្ងៃឈ្មោះប៉ោង?

ខៈប៉ោងហ្នឹង។

កៈមឿនប៉ោង តែពេលមុនឈ្មោះ មឿងមាស។

ខៈចាំ ពីទូចៗគេហៅមឿងមាស ប៉ុន្តែខ្ញុំគេហៅមាសអត់ឆ្លើយសោះ អត់ឆ្លើយទេ។

កៈចាំចឹងអ្នកមីងនៅចាំថាខ្លួនឯងកើតនៅក្នុងឆ្នាំណាទេ?

ខៈញ៉ុមអត់ដឹងប៉ុន្តែញ៉ុមដឹងតែឆ្នាំខ្លួនញ៉ុមថាឆ្នាំម្សាញ់។

កៈឆ្នាំម្សាញ់!!!

ខៈអាយុ៥៣ឆ្នាំនេះហើយ។

កៈចឹងឆ្នាំ២០១៧អាយុ៥៣ឆ្នាំ? ខៈ ចាំ។កៈចឹងប្រហែលជាបើកូនចៅអ្នកមីងស្តាប់ក្រោយទៅគាត់ដកទៅដឹងថាអ្នកមីងកើតឆ្នាំណាហើយ។ចឹងមីងចាំថាកើតខែណាអត់?

ខៈដឹងថាញ៉ុមកើតខែផល្គុន។

កៈខែផល្គុន?

ខៈចាំ។

កៈហ្នឹងហើយ។

ខៈខែផល្គុនឆ្នាំម្សាញ់។

កៈឆ្នាំម្សាញ់ចាំឆ្នាំបារាំងទេ?

ខៈឆ្នាំម្សាញ់។

កៈខែបារាំងប៉ា? មករាដល់ធ្នូហ្នឹងមីងចាំទេ?

ខៈអត់ ញ៉ុមតែខែបារាំងអត់ចេះទេ។សព្វថ្ងៃញ៉ុមខែមួយខែពីរខ្លះ លើកមុនអត់ស្គាល់ទេ។កៈចាំ។ខៈតែគេថាខែបារាំងញ៉ុមអត់យល់ សព្វថ្ងៃវាយល់ខ្លះហើយ ។កៈចាំ។ខៈតែលើកមុនគេសួរខ្ញុំថាកូនកើតខែអី ?ប្រាប់គេជាខែខ្មែរអត់អោយថាវាអត់ស្គាល់នោះ គេធ្លាប់តែខែបារាំងយើងនិយាយខ្មែរគេអត់ស្គាល់ទៅញ៉ុមចុះមិនដឹងនិយាយថាម៉េច ស្គាល់ដែរអត់ចេះដែរ។

កៈហ្នឹងហើយអត់អីទេអ្នកមីង ។

ខៈដឹងតែខែខ្មែររហូត ចាំ។

កៈចឹងអ្នកមីងតើសព្វថ្ងៃនៅភូមិឃុំអីគេដែរ?

ខៈញ៉ុមភូមិឃុំ គោកចក។

កៈមីង ឃុំអីស្រុកអីខេត្តអី?

ខៈភូមិវាល ឃុំគោកចក ខេត្តសៀមរាប ស្រុកសៀមរាប។

កៈហ្នឹងហើយ ចាំចឹងឥឡូវហ្នឹងទីលំនៅបច្ចុប្បន្នហេ?

ខៈចាំហ្នឹងហើយបច្ចុប្បន្នហ្នឹងរាល់ថ្ងៃហ៎ា។

កៈអ្នកមីងប្រាប់ពីទីកន្លែងកំនើតរបស់អ្នកមីងហ៎ាអ្នកមីងកើតនៅទីកន្លែលណាវិញ?

ខៈញ៉ុមនៅនេះឯងនៅកន្លែងដែលញ៉ុមកើត។

កៈពីមុនមកភូមិឃុំដដែលអត់?

ខៈពីមុនមក!!!

កៈគេហៅភូមិឃុំអីគេដែរអ្នកមីង?

ខៈពីមុនដែលញ៉ុមទូចៗ ញ៉ុមស្គាល់តែភូមិត្រពាំងសេះ។កៈ!!! ខៈប៉ុន្តែភូមិឈ្មោះត្រពាំងសេះរហូត យើងប្រែទៅដីថ្មីដែរបានដាក់ភូមិវាល។

កៈឥឡូវនៅទីនេះភូមិវាលចឹងហេ?

ខៈឥឡូវភូមិត្រពាំងសេះ រាល់ថ្ងៃនេះនៅតែភូមិត្រពាំងសេះដដែល។

កៈប៉ុន្តែមីងនៅខាងនេះគេហៅថាភូមិវាល ?

ខៈចាំភូមិវាល។

កៈចឹងមកទីនេះមកលេងផ្ទះកូន។ខៈចាំ។កៈហ្នឹងហើយ ចឹងអ្នកមីងសំរាន់សព្វថ្ងៃអ្នកមីងមុខរបររកស៊ីអីគេដែរ?

ខៈញ៉ុមធ្វើតែស្រែ។

កៈធ្វើតែស្រែ?

ខៈចាំចប់ពីស្រែមកមានតែនំលក់អញ្ចេះៗឯង។

កៈមីងលក់នំអីគេខ្លះវិញ?

ខៈនំចេកនំល្ពៅ នំគម ៣មុខហ្នឹង។

កៈឥឡូវញ៉ុមសួរមួយ មីងប្រាប់ញ៉ុមពីរបៀបដែលធ្វើនំចេកបុកមួយមើល!!!ឥឡូវមីងប្រាប់ថាធ្វើម៉េចខ្លះទៅ?

ខៈញ៉ុមបើខ្លាចតែធ្វើគេ ធ្វើផ្សេងបើញ៉ុម ញ៉ុមលាយម្សៅរួចញ៉ុមដាក់កក្ករនឹងរបៀបនំក្ករណាស់ហ៎ា!!!!កៈចាំ!! ខៈញ៉ុមក្ករម្សៅមួយស្អិតបានញ៉ុមយកមកខ្ចប់។កៈចាំ!!! ខៈបើខ្លះគេប្រលាក់គេខ្ចប់យកចំហុយហ៎ា!!! កៈចាំ!! ខៈញ៉ុមដាក់អញ្ចាសទៅវាចំហុយស្រួលយើងដាក់ជាមួយនំចេកវាឆាប់ឆ្អិនទាំងអស់គ្នា។កៈចាំ!!! ខៈបើយើងប្រលាក់ភ្លាមយកមកដាក់ចំហុយទៅវាឆ្អិនចេកមុន។

ក៖ចាំគេលែងអីគេខ្លះមីងនំហ្នឹង?

ខ៖លាយខ្ទិះដូង លាយខ្ទិះដូចចេកនឹងម្សៅហើយស្ករ។ក៖ចាំ!!! ខ៖បើនំល្ពៅបានគេដាក់លាយកាកដូងដាក់ដូងសាច់វាហ៎ា មិនមែនកាកដូងទេណាស់ ដាក់ដូងទាំងសាច់ គេពូតខ្ទិះតែម្តងដាក់សាច់ទាំងកាក។ក៖ចាំ!!!ខ៖បើចេកបុកញ៉ុមអត់ដាក់ទេ ចេកបុកអត់ត្រូវគ្នាទេ បើនំល្ពៅដាក់ទៅវាត្រូវគ្នា ពេលស៊ីទៅវាប៉ះនឹងអាជាតិដូងហ្នឹងហ៎ា!!!!

ក៖ចាំហ្នឹងហើយវាឆ្ងាញ់។

ខ៖ហ្នឹងហើយ។

ក៖ចាំចឹងចូលដល់ការសិក្សាអ្នកមីង អ្នកមីងរៀនដល់ថ្នាក់ទីប៉ុន្មានដែរអ្នកមីង?អ្នកមីងដែលចូលសាលាអត់?

ខ៖សម័យអាពតអត់ដែលបានចូលសាលាសោះព្រោះអីវាចូលដែរវាមិនមែនថាមិនចូលទេថាពួកនោះដូចថាយើងរៀនមួយម៉ោងអញ្ចេះមួយខែ បើនៅទូចៗវាអត់ស្គាល់រៀនមួយម៉ោងអញ្ចេះក៏ដល់ម៉ោងធ្វូលការទៀតបាត់ ដល់ពេលមកដល់បច្ចុប្បន្នសម័យនេះញ៉ុមសុំម៉ែរៀនអត់បាន គ្រាន់តែយើងចូលស្រុកមក យួនដាច់ យួនដាច់ញ៉ុមអាយុ១៤ ១៥ ១៥ ១៧សុំម៉ែរៀនអត់បាន អត់បានរៀនទេ គាត់បានថាកូនអើយយើងអត់ រៀនធ្វើអីអត់មានឪរកចិញ្ចឹមញ៉ុមអត់បានរផនរហូតអត់បានចេះអក្សររហូត៕

ក៖ចឹងមីងនៅប៉ុល ពតមីងនានអាយុប៉ុន្មានវិញ?

ខ៖ញ៉ុមអាយុ១៣។

ក៖១៣ឆ្នាំ?ខ៖ចាំ!!!ក៖នៅកងកុមារ?

ខ៖នៅកងកុមារ!!!

ក៖ចឹងមីងធ្វើអីគេខ្លះអ្នកមីង?

ខ៖មីងមានតែកាត់ក្របីជីអាចម៏គោ កាប់ផាងខេតដាក់តាមស្រែ។

ក៖ហ្នឹងហើយ។ខ៖ចាំ!!!ក៖កាប់ហើយគេយកទៅជាន់ជាមួយអីអត់មីង?

ខ៖ដីដំបូងគេកាប់ដីដំបូងលាយផាងខេត លាយផាងខេតទៅ គេអ្នកច្រូបាច់ផ្សេង ពួកញ៉ុមគ្រាន់តែម៉ាកាប់ចិញ្ច្រាំអោយគេ។

ក៖ចាំតែប៉ុណ្ណឹងទេ?

ខ៖ចាំ។

ក៖ចាំហើយគេអតើមានអីដែរ តែប៉ុណ្ណឹងអត់មានធ្វើអីទៀតទេចឹង??

ខ៖អត់មានធ្វើអី ដូចថាព្រឹកព្រហាមចេះយើងព្រឹកព្រហាមគេដាក់កំណត់អោយយើងទៅជីកដី៣ម៉ែតទៅ៤ម៉ែតណាស់!!! គេដាក់ផែនការយើងធ្វើអោយរួច បើយើងមិនរួចគេអត់អោយហូបបាយទៅយើងជីកម៉ារួចស្ទើរជង្គង់គេធ្វើរងដាំអំពៅហ៎ា!!!យើងជីករួចយើងមកហ៎ាមិនមែនហូប

បាយទេណាស់ព្រឹកព្រហាមហ៉ា។គេអោយដំឡូងយើងម្នាក់ប្រវែងណេះប្រហែលម៉ាថាមាចង្អាមចុះ។ ក៖ចាំ!! ខ៖ថាម្នាក់មួយកង់ចុះប៉ុនករដៃអ្នកណាអត់ធ្វើអត់បានហូប អត់បានហូបទេដំឡូងប៉ុនហ្នឹងណោះ អត់បានហូបទេបើយើងជីកបាន បើយើររើសនឹងការងារអត់ គេអត់អោយហូបទេ។

ក៖ចាំចឹងមីងដូចជាញ៉ុមដឹងថាមីងអត់បានរៀនមែនប៉ុន្តែមីងបានចង់មែនទេមីង?

ខ៖អូយញ៉ុមចង់ ញ៉ុមសូមម៉ែញ៉ុមឡើង២ ៣ដង ដល់ពេលសុំគាត់ទៅគាត់ថាយើងអត់មានឳរកស៊ីចិញ្ចឹម ។ក៖ចាំ!!! ខ៖ញ៉ុមសុំគាត់២ដងគាត់ថាតែចឹងឯងទៅក៏ញ៉ុមឈប់សុំគាត់ទៅនឹកឃើញគាត់ថាអញ្ចុះទៅធំគ្រាន់ហើយក៏អត់សុំគាត់ទៅ គេរៀនអាយើងសម័យ៨៣ ៨៤(១៩៨៣ ១៩៨៤)គេរើសរៀនអក្ខរកម្មយប់ទៅយប់ឡើងញ៉ុមទៅរៀន រៀនទីនេះឯងរៀននៅមុខផ្ទះមកខាងមាត់ត្រពាំងនេះ។

ក៖ចាំមាត់ត្រពាំងសេះហ្នឹង?

ខ៖ចាំ!!មាត់ត្រពាំង ញ៉ុមនៅទីនេះរៀនទីនេះឯង។

ក៖ចាំហ្នឹងហើយ។

ខ៖ចាំទៅ ទៅយប់ឡើងញ៉ុមស៊ីបាយរួចទាញសៀវភៅខ្ទោកមើលញ៉ុមបើសិនញ៉ុមបានរៀនញ៉ុមប្រាកដថាចេះខ្លួនញ៉ុមម៉ង។ក៖ចាំ!!!ខ៖ដល់ញ៉ុមអត់បានរៀនចេះក៏រៀនអក្ខរកម្មដូចនឹកឃើញប៉ុន្តែគេបង្រៀនបាន១ខែគេឈប់ទៅណាស់!!!អញ្ចុះឯង!!ក៖ចា!!ទៅក៏ញ៉ុមរៀនតែល្ងាចឡើងញ៉ុមទាញសៀវភៅមកមើលកុំអីញ៉ុមមិនទៅដែលបានចេះអក្សរអីបន្តិចទេ!!

ក៖តឡូវចេះអានអត់ចឹង?

ខ៖ញ៉ុមចេះអានកើត។

ក៖តឡូវចេះអានដោយសារអីគេវិញចឹង?

ខ៖ចេះអានដោយសាររៀនអក្ខរកម្មទៅយល់ស្គាល់។

ក៖យល់ហ៎?

ខ៖ចាំ!!!ចេះយលយើងចេះស្រះ ក ខ ចប់ណាស់!!!យើងចេះ ក ខ យើងចេះផ្សំជើងទៅញ៉ុមចេះមើលដាច់បើសិនតែលេខ លេខអត់សូវចេះទេ!!

ក៖អត់អីទេមីងអោយតែអានអក្សរដាច់។

ខ៖អក្សបានអានដាច់ខ្លះហើយដូចពាក្យណាពិបាកខ្លះយើងសួរ យើងអីគេទៅណាស់!!

ក៖ចាំ!!ហ្នឹងហើយ។

ខ៖ ប៉ុន្តែពាក្យណារៀនមិនទាន់ដល់ដូចថាដល់យើងសង្វាគណាស់!!!ដូចថាយើងរៀនឯណោះអត់ទាន់ដល់ទេយើងមើលឯណោះមើលត្រូវ មើលត្រូវរួចបានយើងរៀនដល់។ក៖ចាំ!! ខ៖ញ៉ុមមើលត្រូវរួចបានតើ ញ៉ុមមើលសៀវភៅបានដាច់។

ក៖ហ្នឹងហើយ។

ខះតែល្ងាចឡើងមើលសៀវភៅ ល្ងាចឡើងមើលសៀវភៅ។

កះមីងអាយុប៉ុន្មានពេលរៀនអក្ខរកម្មហ្នឹង?

ខះកាលហ្នឹងញ៉ុមអាយុខ្ទង់២០ទេ។

កះ២០ឆ្នាំហើយហេ?

ខះចា៎!!!

កះចឹងមីងមានដែលធ្លាប់មានក្ដីស្រម៉ៃពេលអនាគតថាហ្ន៎ខ្លួនឯងចេះអានអក្សរប៉ុណ្ណឹងដែរចង់ធ្វើអីមួយអត់?

ខះអូយមិនដែលបានទៅទឹកឃើញអីចុះទេ!!!ប៉ុន្តែដឹងតែយើងអត់យើងទៅរកអី ទឹកឃើញចេះតែស្រម៉ៃណាស់!!!កះចា៎!!ខះញ៉ុមស្រម៉ៃដែលនៅក្មេងណាស់!!ញ៉ុមមួយជីវិតម៉ាវាលទីនេះមានអ្នកណាកំសត់ដូចញ៉ុមទេ មានតែញ៉ុមក៏កំសត់មែន កំសត់ខ្លួនញ៉ុមហើយវានឿយក៏នឿយក្នុងជីវភាពគ្រួសារក៏ពិបាកទៀត ញ៉ុមរាល់ថ្ងៃនេះញ៉ុមបានថាជីវភាពគ្រួសារញ៉ុមពិបាកពិតមែនប៉ុន្តែញ៉ុមអត់ហូប អត់តែលុយចាយទេណាស់រាល់ថ្ងៃ។

កះស្រូវមានពេញជង្រុកហេ៎?

ខះចា៎បើរឿងស្រូវអង្ករអីញ៉ុមហូបមួយភ្លុំញ៉ុមអត់តែលុយចាយទេ ដូចថាញ៉ុមរកអញ្ចេះបានតែមួយចាយៗទេ។កះចា៎!!!ខះតែដល់ពេលដែលយើងអត់រកអត់។កះចា៎!!ខះចុះបើអាលែងទៅចំការមានអី។

កះហ្នឹងហើយ។

ខះមានអត់ បែរទៅកូនគេរកបាន ដូចដឹងស្រាប់ហើយកូនសម័យឥឡូវនេះ ញ៉ុមបានកូនស្រីទេរាល់ថ្ងៃដូចថាញ៉ុមទៅទីណាពឹងវាបានហ៎ា ញ៉ុមទៅចំការអញ្ចេះស៊ីចុកលើវា ប្អូនរៀន២នាក់លើវា។កះចា៎!!ខះចា៎បើកូនអាប្រុសមួយនោះហ្ន៎ញ៉ុមបាត់និយាយ ញ៉ុមអត់និយាយដែលថាអីទេបានប្រពន្ធញ៉ុមអត់ថាសោះ។

កះអត់សួរគន្លងធម៌មីងណោះ?

ខះចា៎ ទឹមបានប្រពន្ធអត់ទាន់បានសែនអោយគេផង គេអោយរក១៣០០!!កះហ្ន៎!!ខះមិនទាន់មានអោយគេផង។កះចា៎!!!ខះក៏ញ៉ុមចេះតែថាទៅសព្វថ្ងៃណាស់ បើអានៅនេះយកលុយយកទៅអោយគេហើយ វ៉ាយម៉ែ យកម៉ែចិញ្ចឹមកូនតាំងពីរទូចរហូតដល់ធំយកប្រពន្ធទៀតយកម៉ែយកមកអោយម៉ែចិញ្ចឹមទៀត ចុះបើម៉ែទៅបាត់បានអ្នកណាអ្នកចិញ្ចឹម មិនងាប់បងទុកបងដូច ម៉ែទៀតណាស់!!! មីងទៅគេថាអោយទៀត។កះចា៎!!!ខះទៅរកការងារអីធ្វើបាត់ហើយ ធ្វើការងារ២ឆ្នាំតែគេបោក។កះអូយ៎!!ខះគឺគ្នាធ្វើការរួចចេះទៅគេអត់បើកលុយអោយ។

កះនៅឯណាវិញមីងធ្វើការហ្នឹង?

ខះធ្វើការនៅហ្នឹងយើងក្នុងខេត្តនេះ។

ក៖ខេត្តសៀមរាបហ្នឹងហេ៎?

ខ៖ធ្វើការ មើលធ្វើការកាលឆ្នាំទៅមិញធ្វើមេងណោះ ធ្វើមេជ្លួងយើង ដល់ពេលគ្នាទៅបើកលុ យម្ដង៥០ អោយម្ដង៥០ លុយឡើងរាប់ លុយឡើងចង់ពាន់ណាស់អោយម្ដង៥០ នៅជាប់១០០ លោះឥឡូវអត់សងទេ!!!គេអត់អោយទៀត ដល់នេះគេនេះទៀតណាស់ គ្នាធ្វើ ការបានឡើង២ ៣០០កាលបិណ្ឌអត់បើកអោយគ្នាទៀត ដល់ពេលទៅបើកហ៊ុចាំថ្ងៃនេះចាំថ្ងៃ នោះនៅជាប់នោះប្រហែល២០០ទៀត ។

ក៖យ៉ាប់ណាស់មីងណោះ?

ខ៖ចា៎!!!អាគ្នាធ្វើបុណ្យទាំងមូលអត់បើកលុយអោយគ្នា ។ក៖ចា៎!!!ខ៖ញ៉ុមតែខែនេះឡើងណាស់បានលុយរស់នឹងអានំចេកហ្នឹងឯង។

ក៖លក់នំចេករាល់ថ្ងៃហ្នឹងហេ?

ខ៖ចា៎លក់នំចេករាល់ថ្ងៃញ៉ុមបានរស់រាល់តែឆ្នាំ ដូចថាជិតបុណ្យចេះទៅយើងធ្លាក់រករាល់ថ្ងៃគេយក៤ ១០ណោះ ៤ ១០ណោះ ២០ ៣០ទៅណាស់ ។ក៖ចា៎!!!ខ៖បានលុយនោះឯងបានធ្វើ បុណ្យ។

ក៖អោយកូនចៅជំនាន់ក្រោយៗនេះដឹងថាម៉ែរស់ដោយសារលក់នំចេក។

ខ៖ចឹងឯងបើសិនញ៉ុមទៅចំការបាត់ទៅបានកូនញ៉ុមមីមួយនោះ មើលថែប្អូនរៀនទៅ ចាំបាយទឹកម្ហូបលើវាយើងមានតែបាយអោយវាទេណាស់!!!អាលុយចាយក្រៅសុទ្ធតែវារកចិញ្ចឹមបងប្អូន។ក៖ចា៎!!!ខ៖មីមួយហ្នឹង ទឹមបានប្ដីបែក២ឆ្នាំ ទឹមបែកពីរឆ្នាំនេះឯង។

ក៖ចា៎ចឹងអ្នកមីងអ្នកមីងរៀបការឆ្នាំណាវិញ?

ខ៖ញ៉ុម៨៥។

ក៖១៩៨៥?ខ៖ចា៎!!ក៖ហ្នឹងហើយ ហើយរៀបការមានកូនប៉ុន្មាននាក់ហើយ?ខ៖៦!!ក៖៦នាក់?

ខ៖ចា៎!!ក៖ស្រីប៉ុន្មានប្រុសប៉ុន្មានមីង?

ខ៖ស្រីតែ២ទេ។

ក៖ស្រីតែ២ទេ?

ខ៖ចា៎ ប្រុស៤។

ក៖មីងចាំឈ្មោះកូនទាំងអស់តើមែនទេ?ខ៖ចា៎!!!ក៖ចឹងមីងអាចប្រាប់ឈ្មោះរបស់កូនតាំងពីរបងគេរហូតដល់ពៅគេតើគាត់ឈ្មោះអីគេដែរទាំងត្រកូលរបស់គាត់ហ៎ា?

ខ៖ចា៎។

ក៖ទី១ឈ្មោះអីដែរ?

ខ៖ទី១ឈ្មោះ ហឿម ហ៊ុញ ទី២ ហឿម ថោង ទី៣ ហឿម សោម ទី៤ធា។

ក៖អីគេធា?

ខ៖ហឿម ធា ទី៥ហឿម ហ៊ុន ទី៦ហឿម ហូន។

ក៖ចាំហើយពួកគាត់ទាំងអស់ តើបងគេគាត់អាយុប៉ុន្មានវិញមីង?

ខ៖អាយុ៣០ហើយ។

ក៖ចុះពៅគេ?

ខ៖ពៅគេទឹមតែអាយុ១៤ឆ្នាំថ្មីនេះ។

ក៖ចាំហ្អឹងហើយ។

ខ៖ចូលឆ្នាំថ្មីចូល១៥។

ក៖ចឹងអ្នកមីងរៀបការជាមួយលោកពូហ្អឹងរៀបការម្ដាយជាអ្នករៀបចំអោយឬក៏ស្រលាញ់គាត់ដូចជាស្រលាញ់ហើយបានអោយឪពុកម្ដាយដឹងចូលរៀបការ?

ខ៖អត់ គេចូលត្រឹមត្រូវ។

ក៖គេចូលស្ដីដណ្ដឹងទៅ?

ខ៖ចាំ!!!គេចូលត្រឹមត្រូវម៉ែញ៉ុមមិនចង់អោយផង ប៉ុន្ដែដូចថាគូររបស់យើង។ក៖ចាំ!!ខ៖គេមិនអោយគាត់មិនអោយក៏យើងមិនហ៊ានរត់យកគេដែរប៉ុន្ដែថាក្នុងចិត្តថាគាត់មិនអោយដូចថាយើងនៅពីក្មេងយើងឆោតនោះ គ្រាន់តែថាគេចូលសួរយើងពេញផ្ទះភ្លាមល្បីហ៎ា!!យើងគេសួរហើយមិនល្បីល្បីថាមីនេះគេចូលសួរចេះចុះណាស់!!!ខ្មាសគេដែរញ៉ុមណាស់!!!គ្រាន់តែគេចូលសួរដល់ផ្ទះភ្លាមល្បីដល់តែទីនេះ ល្បីគេថាល្បីទីណោះគេថាទៅ អៀលគេទៅណាស់!!អៀលគេថាហ៊ីបើសិនជាអត់បានវិញអញអៀលគេងាប់ហើយ អញ្ចឹងហ៎ា!!!

ក៖អៀលគេ?អៀនមែន?

ខ៖ខ្មាស់គេហ្អឹងហ៎ា។ក៖អៀន!!!ខ៖ហ្អឹងហើយអៀនគេនោះណ៎ា!!អ្ហ៎អញបើអត់បានគេអញអៀនងាប់ហើយអញ្ចេកទៅណា នឹងឃើញតែក្នុងចិត្តឯងទៅណាស់!!!ទៅទីនេះគេបង្អាប់ទៅទីនោះគេបង្អាប់ចុះស្រុកនៅជាមួយគ្នានេះឯង ប្ដីញ៉ុមផ្ទះនៅទីណោះ ឃើញថានៅក្មេងមករែកនំបញ្ចុកលក់នោះ!!រែកនំបញ្ចុកលក់ដឹងថាទៅដល់ផ្ទះរបស់ប្ដីញ៉ុមហើយនោះទៅវៀងឯណោះអត់ចូលទេ បងថ្លៃញ៉ុមថាប៉ុននេះហើយអញដាច់ពោះហើយនំបញ្ចុកអត់ដែលបានស៊ីទេ!!!រែកវៀងរហូត ញ៉ុមមិនមែនដូចក្មេងសព្វថ្ងៃទេ គេត្រូវណា លោះឥឡូវនេះ។

ខ៖លួចអៀន ហើយពេលអៀនហ្អឹងមានលួចស្រលាញ់ប្ដីខ្លះទេពេលហ្អឹង?

ខះអត់ដូចថាយើង ស្រលាញ់ដូចមិនចេះស្រលាញ់ដូចនឹកឃើញស្រណោះ។កះចាំ!!ខះប៉ុននោះឯង។

កះនឹកឃើញអានិតគេ។

ខះចាំនឹកឃើញអានិតដូចថាស្រលាញ់ រកនឹកថាស្រលាញ់ម៉េចនឹកឃើញថាស្រណោះដែលថាអញ្ចេក កុំអីញ៉ុមអត់ទេប្រវត្តិញ៉ុមណាស់!!!ប្តីញ៉ុមចូលសួរញ៉ុមអញ្ចេះម៉ែញ៉ុមគាត់អត់ចង់អោយណាស់!!! សួរ២ដង ដើរមើលគ្រូឯណោះដើរមើលគ្រូឯណេះរហូតទៅណាស់!!ទៅម៉ែញ៉ុមគាត់អត់ចង់អោយទៅក៏ដល់ពេលទៅមើលអ៊ីញ៉ុម អ៊ីញ៉ុមវាស្រណោះវានឿយពេកនោះ ហ៊ុំថាអោ យត្រូវហើយអោយក៏អោយទៅអ៊ីញ៉ុមណាស់ថាអញ្ចេះ ម៉ែញ៉ុមអោយញ៉ុមទាំងខឹងទៀតថា ថាបើគេចូលសួរថាណែសំរេចដៃញកុំថានៅណាស់!!!កុំប្រាប់ថាអញអ្នកអោយណ៎ា!!!ថាអត់នៅទេម៉ែញ៉ុមបង្គាប់អញ្ចេះទៀតណាស់!!!ដល់ពេលគេចូលសួរមកដល់ក៏ ញ៉ុមថាមិនដឹងស្រេចតែ ម៉ែទៅគាត់ខឹងញ៉ុមទៀត គាត់ថាដៃញអញប្រាប់ដៃញកកោកហើយនៅថាស្រេចតែនឹងអញមានតែអញអោយ គាត់អោយញ៉ុមទាំងខឹង ចាំអោយគេទាំងខឹងទេ!!!អោយទាំងខឹង។

កះខឹងទៀត?

ខះចាំអោយទាំងខឹងក៏ញ៉ុមមិនថាអី។

កះតែម៉ែមឹងអត់ចង់អោយទៅដែរ?ចឹទៅ?

ខះអត់ អត់ដឹងថាគាត់រម៉េចថាគាត់អត់ពេញចិត្តដំនើរ។

កះអត់ពេញចិត្តកូនប្រសារហ្នឹងដែរ?

ខះប្រហែលអញ្ចោះបានគាត់មិនអោយ។

កះហ្នឹងហើយ។

ខះហ្នឹងហើយញ៉ុមទៅគាត់ថាអញ្ចោះញ៉ុមក៏មិនប្រកែកមិនអីដែរ!!ដល់ពេលនឹកឃើញថាគាត់អោយហើយពេលយើងខឹងយើងឈ្លោះយ៉ាងណាយើងទុកតែក្នុងពោះយើងអត់និយាយយើងអត់ស្តីណាស់!!កះចាំ!!ខះដូចថាយើងខឹងនឹងប្តីប្រពន្ធយើងយ៉ាងណាក៏មិនហ៊ាននិយាយប្រាប់ម៉ែដែរព្រោះអីយើងយកគាត់មានទៅទុកដាក់អីអោយយើងណ៎ាគាត់អត់ពេញចិត្តណាស់!! កះចាំ!!!ខះបើយើងទៅប្រាប់គាត់ទៅគាត់បញ្ឆួសអោយយើងវិញមិនចឹង!!!

កះថាអត់ស្តាប់គាត់។

ខះនោះឯង មកពីដៃញ អញថាមិនស្តាប់ គាត់ថាអោយយើងអញ្ចេះវិញ។

កះហ្នឹងហើយ។

ខះដល់ហើយថាខុសត្រូវយ៉ាងណាញ៉ុមអត់និយាយ ចាំញ៉ុមអត់និយាយសូម្បីតែប្តីធ្វើបាបម៉េចក៏មិននិយាយ។

ក៖ហ្នឹងហើយ ឥឡូវដូចម៉េមួយ ដូចម៉េយាំងមួយហើយមែនទេ?ខ៖ចំា!!ក៖ចឹងប៉ុន្តែដល់ពេលមីងរៀបការហើយតើមីងស្រលាញ់គាត់អត់ ស្រលាញ់ប្តីអត់?

ខ៖ស្រលាញ់ធម្មតា ។

ក៖ធម្មតា?ខ៖ចំា!!ក៖ហើយថាតើប្តីអ្នកមីងគាត់ឈ្មោះអីគេដែរ?

ខ៖ឈ្មោះហឿម។

ក៖អីគេហឿម?

ខ៖គ្រីម។

ក៖គ្រីមហឿម?

ខ៖ហ៊ី ត្រីគ្រីម។

ក៖ឈ្មោះគាត់រាងកំប្លែងបន្តិចមីងណោះ?ចំាចឹងបន្ទាប់ពីមីងរៀបការហើយសុភមង្គលក៏ដូចជាតើអត្តចរិកស្វាមីរបស់អ្នកមីងគាត់មើលថៃអ្នកមីងឬក៏ម៉េចដែរចឹងហ៎ា?

ខ៖មានអីធម្មតា ប៉ុន្តែដូចថាប្តីញ៉ុមបើរឿងបំរើប្រពន្ធអត់ អត់សូវចេះបំរើទេ ប៉ុន្តែថាវាមិនចេះបំ រើទេដូចថាយើងសរសៃខ្ចីអញ្ចេះ បំរើតែពេលយើងទឹកអុសអីទេណាស់!!! រឿងវាបោកខោអាវ អីញ៉ុមវាមិនប្រើមិនចេះប្រើតែម្តង ញ៉ុមមិនដែលបានប្តីញ៉ុមបោកខោអាវអោយញ៉ុមទេ។ក៖ចំា!!
ខ៖ញ៉ុមកូនង៉ាថ្ងៃណេះញ៉ុមបោកថ្ងៃណេះខ្លួនឯងរហូត ទាំងកន្ទប ខោអាវអីមួយចប់។

ក៖ចុះគាត់អត់រវល់ជាមួយទេចុះ?

ខ៖អត់ទេ ដូចថាយើងនៅភ្លើងបាន៥ថ្ងៃអញ្ចេះគេទៅធ្វើការបាត់ទៅ ហ្នឹងធ្វើការងារបាត់ញ៉ុមអត់ដែលប្រើអត់ដែលនេះទេ ក្រោកឡើងទឹកពេញពាងអញ្ចេះទៅ ញ៉ុមអោយតែថាព្រឹកព្រហាមអីអញ្ចេះដែលយើងនៅក្នុងភ្លើងណាស់!!!គេបំរើយើងបានតែ៥ថ្ងៃទេ ក្រោកឡើងគាត់ដាំតែទឹកអោយញ៉ុមបោកកន្ទបបោកសារុងអីរួចមុជទឹកខ្លួនឯងយកទៅហាល ដែលយើងអត់ទាន់ចេញភ្លើងនោះចំា!!បើញ៉ុមចេញភ្លើងហើយ ញ៉ុមចេញថ្ងៃណោះគឺដាំបាយថ្ងៃណោះហ្នឹងឯងអត់ដែលបានថាប្តីនៅដេកបំរើអីអត់ដែលមានសោះ។ក៖ចំា!!ខ៖កាលពេលហ្នឹងយើងអត់នោះ។

ក៖ចំាហ្នឹងហើយ បើគាត់មិនទៅរកអត់មានអីហូប?

ខ៖ចំា បើយើងមិនអោយប្តីទៅនៅតែមើលយើងបានអីហូប។ក៖ចំា!!!ខ៖ហើយពេលហ្នឹងស្វាមីអ្នកមីងគាត់ធ្វើការអីគេដែរ?

ខ៖កាលនោះធ្វើការផ្ទះយើងធម្មតា ធ្វើអាផ្ទះអញ្ចេះឯង ធ្វើជាងផ្ទះ។

ក៖ជាងសំនង់ចឹងទៅ?

ខ៖ចំាជាងបូក ប៉ុនយើងសព្វថ្ងៃថាជាងសំនង់ណ៎ា!! នៅឯណោះសុទ្ធតែផ្ទះយើងឈើនោះ។

ក៖ហ្នឹងហើយ។

ខ៖យើងដើរធ្វើផ្ទះអញ្ចេះឯង ជាកាលីគេនោះណាស់!!ក៖ចាំ!!ខ៖គេថាមួយថ្ងៃ២០រៀលកាលនោះណាស់!!

ក៖២០រៀលជំនាន់មុន?

ខ៖ជំនាន់មុនណាស់!!

ក៖ចាំមិនមែន២០ដុល្លារនោះទេ។

ខ៖ដូចថាគេចេះគេបាន២៥ ៣០ទៅណាស់!!!ក៖ចាំ!!ខ៖យើងអត់ចេះបានត្រឹម២០រៀល។ក៖ចាំ!!!ខ៖បានតែប៉ុណ្ណោះឯង។

ក៖ចឹងបានរាងគ្រាន់ដែរមីងហេ៎!!!!ខ៖ចាំ!!ក៖ហើយអាចផ្គត់ផ្គង់មីងជំនាន់ហ្នឹងបានមែនទេ?

ខ៖បានហូបបាន ដូចថាអាឈប់ធ្វើពីការងារគេ យើងដាច់ការងារទៅដឹកអុសលក់ ដឹកអុសលក់ក្នុងមួយថ្ងៃបាន៧០ ៩០។

ក៖រៀល ច្រើនហាណាស់!!!!

ខ៖ច្រើនបើយើងទិញអង្ករហូប ម្ហូបអស់តែ៥រៀលទេ ។ក៖ហ្ហ៎!!!!ខ៖ម្ហូបអស់តែ៥រៀល អង្ករយើងទិញតែ១០គីឡូយើងអស់តែ៤០រៀលទេ!!!ក៖ចាំ!!ខ៖១០គីឡូយើងមិនមែនស៊ីតែមួយថ្ងៃអស់ឯណា៎!!!មួយខែ។

ក៖អ្នកណាគេហូបអង្ករ១០គីឡូក្នុងមួយថ្ងៃមីងណោះ?

ខ៖១០គីឡូ២នាក់១ខែណោះបានអស់។ក៖ចាំ!!ខ៖ត្រឹមយើងបានមកដុតដៃដុតជើងមកវេទនាណាស់សព្វថ្ងៃនេះ!!!វេទនាណាស់ ណា៎!!

ក៖ចាំភ្លេចសួរមិញ ម្ដាយរបស់អ្នកមីងវិញ ម្ដាយរបស់អ្នកមីងគាត់ឈ្មោះអីគេដែរ?

ខ៖ម្ដាយញ៉ុមឈ្មោះ រស់។

ក៖អីគេរស់វិញ?

ខ៖ខាន់។

ក៖ខាន់ រស់?

ខ៖ខាន់ រស់។

ក៖គាត់ស្លាប់ឬក៏រស់អ្នកមីង?

ខ៖នៅទេ នៅរាល់ថ្ងៃប៉ុន្តែគាត់ចាស់ហើយ សព្វថ្ងៃគាត់អាយុ៧០ជាងហើយ!!!

ក៖៧០ប៉ុន្មានវិញអ្នកមីង?

ខ៖ម៉ែ៧៧ហើយ។

ក៖ចំា!!!ចាំឆ្នាំគាត់កើតទេ?

ខ៖ញ៉ុមចាំប៉ុន្តែអត់ស្គាល់ខែស្គាល់តែឆ្នាំ។

ក៖ឆ្នាំអីគេវិញមីង?

ខ៖គាត់ឆ្នាំរក។

ក៖ឆ្នាំរក?ខ៖ចំា!!ក៖ប្រហែលជាខ្ទង់ប៉ុន្មានវិញមីងណោះ?គាត់បងមីងប៉ុន្មានឆ្នាំដឹងអត់?

ខ៖ហ្ហុំចុះបើគាត់ឡើង៧០ទៅហើយ។

ក៖ហើយមីងឥឡូវ៥៣។

ក៖ចំាចឹងបងមីងប្រហែល២០ជាង!!!

ខ៖ម៉ែ៧៨ហើយ បើមិន៧៧ ៧៨។

ក៖ចំាហ្នឹងហើយ!!

ខ៖ហើយគាត់ចាស់ហើយ!!!

ក៖ចឹងមានអនុស្សាវរីយ៍អីខ្លះជាមួយគាត់ម្តាយរបស់អ្នកមីងហ៎ា!!!គាត់ជាម្តាយយ៉ាងម៉េចហើយអប់រំថែទាំអ្នកមីងម៉េចដែរ?

ខ៖ម៉ែញ៉ុមគាត់មានទៅកាចអីប៉ុន្តែគាត់
គាត់មិនដែលចេះថាអីអោយញ៉ុមផងញ៉ុមកើតមកមាជី
វិតនេះម៉ែញ៉ុមអត់ដែលបានជេរញ៉ុមទេ!!!ព្រោះអីញ៉ុមធ្វើមិនដែលអោយគាត់ពិបាកគាត់ប្រើផង
ក៖ចំា!!!ខ៖ចំាអត់ដែលពិបាកគាត់ប្រើមែន គាត់ប្រើធ្វើអីញ៉ុមធ្វើមុនមិនចេះអោយ
ដូចថាមុនចេ ញទៅធ្វើការអីចេះ ការងារផ្ទះញ៉ុមក្រោកទៅធ្វើរួចអស់បានញ៉ូមទៅ។

ក៖អ្នកមីងកូនល្អ!!

ខ៖ញ៉ុមរែកទឹក រែកអីទុកអោយគាត់អស់បោសប្រាស់រួចផ្ទះសម្បែងមកដល់គាត់ គាត់នៅផ្ទះដាំតែបាយហូបហ្នឹងឯង ។ក៖ចំា!!!ខ៖ញ៉ុមមុនមកពីធ្វើការអញ្ចេះញ៉ុមរែកទឹកទុកអោយគាត់សម័យយើងកាលនោះក្រទឹកណាស់!!!ក៖ចំា!!ខ៖មិនមែនដូចសម័យយើងកាលពីឥឡូវនេះទេ ទឹកនោះទៅរែកភូមិវាល។ក៖ចំា!!!ខ៖អណ្តូងណោះទៅរែកឯណោះ ចំាអត់មានសំបូរដូចសព្វថ្ងៃទេ!!ចំា!!ក៖ចំា!!ខ៖ក្រទឹកណាស់សម័យញ៉ុមនោះ បើរែកទឹកវិញញ៉ុមប្រាប់តែម៉ោង៣ញ៉ុមក្រោករែករួចហើយ នេះអណ្តូងយើងទីនេះណាស់!!!!តែម៉ោង៣ក្រោករែក អណ្តូងមិនមែនចេញទឹកហ៊ូឯណា អណ្តូងចេញទឹកមកស្រឹមៗ។ក៖ចំា!!ខ៖តែម៉ោង៣ញ៉ុមក្រោករែក តែម៉ោង៤ម៉ោង៥ញ៉ុមរែកទឹកហើយអស់!!!ញ៉ុមរែកទឹកចាក់ទឹកចាក់ធុងអីអស់ហើយ អត់ឯណាអត់ទៅ

អោយតែបានផ្ទះញ៉ុម។ក៖ចា៎!!ខ៖ញ៉ុមរែកចាក់អស់ហើយ រែកស្រោចស្លា ស្រោចម្លូរ។ក៖ចា៎!!! ខ៖រែកស្រោចអស់ញ៉ុមរែកទៅក្រោយមួយអំរែកទុកក្នុងឡាំងចាក់អោយពេញៗអស់ហើយនោះ។ក៖ចា៎!!ខ៖ចា៎!!!មិនដែលពិបាកម៉ែញ៉ុម មិនដែលពិបាកទេ ញ៉ុមនិយាយអោយត្រង់។

ក៖ចា៎!!!ចឹងមីងអ្វីដែលមីងចងចាំបំផុតជាមួយម្តាយដែលមីងស្រលាញ់គាត់ជាងគេនៅត្រង់ចំណុចណា?

ខ៖ញ៉ុម ម៉ែញ៉ុម!!!ក៖ចា៎!!ខ៖ញ៉ុមស្រលាញ់តែគាត់ គាត់បានតែកាចតែមាត់ទេ។

ក៖កាចតែមាត់។

ខ៖ចាំបើមានអីអោយកូនហូបអស់ មិនថាកូនប្រសារមិនថាកូនបង្កើត មិនថាអ្នកផ្សេងទេម៉ែញ៉ុ មអ្នកក្រៅអោយតែមានអោយគេហូបអស់!!!

ក៖ហ្នឹងហើយ ចុះសំរាប់ឪពុកមីងវិញម្តងគាត់ឈ្មោះអីគេវិញ?

ខ៖ឪពុកញ៉ុមស្លាប់តាំងពីញ៉ុមនៅទូចៗប៉ុននេះ។

ក៖តែចាំឈ្មោះគាត់ទេ?

ខ៖ចាំ។ក៖ឈ្មោះអីវិញ?

ខ៖ឈ្មោះមឿន។

ក៖មឿនអីគេវិញ?

ខ៖សួង មឿន។

ក៖សួង មឿន?

ខ៖ចា៎!!!ឪគាត់ឈ្មោះសួង។

ក៖ចាំមីងនៅពីតូចចឹងមានចាំអីគេខ្លះអនុស្សាវរីយ៍ជាមួយឪពុករបស់អ្នកមីង?

ខ៖ញ៉ុមអត់ដែលទៅបានចាំអីទេញ៉ុមនៅទូចៗ កាលនោះដឹងតែកាលគាត់នៅជុំយើងណាស់!!

ក៖ចា៎!!!ខ៖កាលណោះដែលញ៉ុមប៉ុនៗនេះហើយអត់បានសូវជួបគាត់ទេ បែករហូត។

ក៖ម៉េចបានចឹងវិញ?

ខ៖ចុះគេចល័តនោះ។

ក៖ជំនាន់ប៉ុល ពត?

ខៈចា៎!!!ចល័តគាត់នៅផ្សេងញុំមនៅផ្សេងទៅ ចាំម៉ែក្រោកឡើងចេញបាត់ ពេលយប់មកដល់ប៉ះណាគេអោយ២ ៣ថ្ងៃមកដេកផ្ទះបានមួយយប់ កាលណាទៅរាប់ខែមិនមែនទៅ១ ថ្ងៃ២ទេណាស់!!!

កៈមិនមែនគាត់ចង់ទេតែគេចាត់ទៅមីងណោះ?

ខៈចា៎គេចាត់អោយទៅ បើយើងមិនទៅអត់បាយហូប ចុះនៅផ្ទះបានអីហូប ចា៎!!

កៈពិបាកណាស់ចឹង!!!មីងចាំថាគាត់កើតឆ្នាំអីគេអត់?

ខៈញុំមអត់ អត់ស្គាល់ដែរ។

កៈឆ្នាំខ្មែរអីចឹងហ៎ាជូត ឆ្លូវ ខាល ថោះអីហ្នឹង?

ខៈស្គាល់ឪញុំមឆ្នាំជូត។

កៈឆ្នាំជូត?

ខៈចា៎!!!បើម៉ែញុំមឆ្នាំរក ញុំមស្គាល់ទាំងអស់បើគាត់និយាយបានស្គាល់។

កៈចា៎ហើយម៉ែឪហ្នឹងបងប្អូនគ្នាតើម្ដាយបងឬក៏ឪពុកបង?

ខៈឪពុក។

កៈចឹងឪពុកបងម្ដាយ ម្ដាយអ្នកមីងឆ្នាំរក?ខៈចា៎!!កៈហើយប៉ាអ្នកមីងឆ្នាំជូត។

ខៈឆ្នាំជូត។

កៈចឹងឆ្ងាយពីគ្នាដែរតើមីង។

ខៈឆ្ងាយ ៩ឆ្នាំ ៩ឆ្នាំជិត១០។

កៈហ្នឹងហើយ ខ្ទង់ប៉ុនៗហ្នឹងចឹងហ៎ា!!បើសិនជាកូនចៅចង់ដឹងដកអាយុគាត់ទៅដឹងអាយុគាត់ប៉ុន្មានហើយ។ខៈចា៎!!!កៈបើសិនជាចង់ដឹងថាឪពុកកើតឆ្នាំអីចឹងហ៎ា!!!

ខៈឪញុំមងាប់ជំនាន់អាពត ស្មាទោសដូចខ្មោចឆ្កែដូចខ្មោចឆ្មាចឹង។

កៈម៉េចវិញទៅមីងតើអ្នកមីងអាចរៀបរាប់ប្រាប់បានទេ?

ខៈចុះបើមិនបានឃើញហ្ន៎ បើគេដឹកយកទៅមិនបានឃើញ មិនដឹងងាប់ឯណាចោលឯណាផង គេអត់អោយយើងទៅតាមទេ!!!

កៈមីងមានឮដំណឹងអីខ្លះអត់។

ខៈអត់ ដូចថាងាប់ទៅ គេប្រាប់ថាងាប់គេមានដែលអោយយើងបានទៅឃើញមនុស្សអត់ ហើយញុំមនៅតូចប៉ុនៗនេះហ្ន៎!!អត់ទាន់ចេះគិតអីគេប្រាប់ថាងាប់ក៏ងាប់ទៅណាស់!!!

កះហើយអត់មានពិបាកអីទេហី?

ខះចំាដូចអត់មានចេះថាគិតអីទេណាស់!! ឪអញងាប់អត់ចេះគិតម៉េចទេ!!អត់ចេះគិតទេគ្រាន់តែគេប្រាប់ថាឪយើងងាប់ហើយ ហ៊ុងាប់ហើយក៏ងាប់ ហ៊ុអញ្ចេកទៅណាស់!!!

កះហើយអត់មានយំអត់មានអីទេចុះ?

ខះអត់មានចេះគិតអីថាឪអញងាប់រម៉េចៗអត់មានចេះគិតទេ លុះគ្រាដល់ធំបានចេះនឹកឃើញក្រោយ គិតថាហ៊ុឪអញងាប់ដែលថ្ងៃគាត់យកទៅពេទ្យហ្នឹងបានឃើញមុខគាត់តែប៉ុណ្ណោះ ឯងឃើញមុខគាត់ដែលគេដឹកមកពេទ្យនោះឯង ឃើញទៅមកដល់សង្ហារដែលគាត់ក្រោកអត់រួចណាស់!!!គាតស្រវារកហៅសួររកកូនហ៎ា!!!គាត់និយាយអត់ឮទេ គាត់និយាយរសាវៗ និយាយអត់ឮទេ ខ្សាវៗទៅក៏ ញ៉ុមឃើញថាឪញ៉ុមចុះរត់ប្រុយមក រត់ប្រុយមកផ្ទះវិញណាស់ដូចថាផ្លូវមុខផ្ទះចេះឯង ផ្ទះមិនឆ្ងាយ ផ្ទះដូចរោងនេះឯងដូចអញ្ចេះឯងទៅដល់ក៏ឃើញតែឪចុះក៏រត់ប្រុយមកវិញ អង្គុមហាន់អាដើមថ្នាំយើងហ្នឹងហ៎ា!! អង្គុយហាន់ បណ្ដើរដកដង្ហើម គេថាណោះគេដឹកឪងែញមកពេទ្យហើយ រត់ប្រុយទៅមើល គេដឹករទេះណាស់ ដល់ទៅមើលក៏ឃើញឪក្រោកអត់រួចក៏រត់មកវិញប្រុយ អង្គុយហាន់ថ្នាំបណ្ដើរយំបណ្ដើរជក់នោះណាស់ ហាន់ថ្នាំបណ្ដើរជូតទឹកភ្នែកបណ្ដើរ គេថាម៉េចងែញយំ ហ៊ុអញឆ្ងួលដើមថ្នាំ កុហកគេណាស់!!! ការពិតយំទេម៉េចបានងែញចេញទឹកភ្នែក? អញឆ្ងួលអាប្រែកថ្នាំនោះទេ!!!

កះចំាហើយហាន់ថ្នាំហ្នឹងធ្វើអីគេវិញមីង?

ខះហាន់ថ្នាំជក់យើងហ្នឹង។កះហ្ន៎!!ខះចំា!!!

កះជក់ខ្លួនឯងឬក៏អោយអ្នកណាគេ?

ខះទេហាន់ទុកអោយម៉ែគាត់ទល់។កះហ្ន៎!!!ខះដឹងតែប៉ុណ្ណោះឯង មិនដែលបានឃើញគាត់ទៀ ត។

កះឥឡូវឪពុកម្ដាយចប់ហើយចូលដល់ម្ដាយឪពុកខាងម្ដាយរបស់មីងហ៎ាចាំថាតាឈ្មោះអីយាយឈ្មោះអីទេមីង?

ខះអត់ស្គាល់។

កះអត់ស្គាល់ ហើយកើតទាន់តាយាយហ្នឹងអត់?

ខះអត់។ហ្ន៎ញ៉ុមស្គាល់ ស្គាល់តែត្រឹមម៉ែ ម៉ែញ៉ុមទៅទៀតណាស់!!!

កះចំាហ្នឹងហើយៗ។

ខះចំាស្គាល់ ស្គាល់ត្រឹមម៉ែម៉ែញ៉ុមស្គាល់ឈ្មោះ ប៉ាន់។

កះយាយប៉ាន់ចំាម៉ែញ៉ុមត្រូវជាយាយញ៉ុមឈ្មោះប៉ាន។

ខះបើឪគាត់ឈ្មោះខាន់។

កះខាន់?ខះចំា!!កះអត់ចាំត្រកូលគាត់ទេហេ?

ខះចាំត្រកូលតាហ្នឹងអត់ស្គាល់ទេញ៉ុម។កះចំា!!!ខះចំា។

កះកើតទាន់គាត់២នាក់ហ្នឹងអត់?

ខះចំាញ៉ុមទាន់យាយបើតាអត់ទាន់ទេ។

កះចឹងមានអនុស្សាវរីយ៍អីគេខ្លះជាមួយយាយវិញមីង?

ខះអ៊ូយាយញ៉ុមបែកគ្នាដែរ។

កះម៉េចវិញទៅ?

ខះជំនាន់អាពតគាត់នៅផ្សេងញ៉ុមនៅផ្សេង។

កះចំាចុះអាពតអត់ទាន់ជំនាន់អាពតហ្នឹងមីងវិញ?

ខះអត់ទាន់ជំនាន់អាពតគាត់នៅជាមួយម៉ែ។កះចំា!!!ខះនៅហ្នឹងយើងនេះឯងញ៉ុមកាលហ្នឹងនៅតូចអាយុ៧ឆ្នាំតែញ៉ុមចាំបាន ញ៉ុមអាយុ៧ឆ្នាំគេជំលៀសទៅនៅក្នុងវត្តអង្គរយើងហ៎ា!!!

កះនៅក្នុងអង្គរហ្នឹងម៉ង?

ខះចំានៅក្នុងអង្គរហ្នឹងម៉ង នៅក្នុងអង្គរពេលគ្រាប់បន្តក់មកនាំគ្នារត់ឡើងលើអង្គរ។កះចំា!!ខះចំាកាលហ្នឹងញ៉ុមអត់ទាន់អាយុ៧ឆ្នាំទេ។

កះហ្នឹងជំនាន់លន់ នល់ឬក៏ប៉ុល ពត?

ខះជំនាន់លន់ នល់កាលហ្នឹង។

កះលន់ នល់!!!! ចឹងមីងនៅក្នុងប្រាសាទអង្គរវត្តយើងហ្នឹងក្រោយខ្នងយើងនេះហ្នឹងហិ តើមានគ្រាប់ដែលធ្លាក់ចំប្រាសាទហ្នឹងអត់?ខះអត់!!កះអត់មានសោះហេ?

ខះអត់មាន។

កះបើធ្លាក់វិញខូចទ្រង់ទ្រាយអស់ហើយមីងណេះ?

ខះចំា!!!លឺតែគ្រាប់បន្តក់លឺហោះប៉ុន្តែអត់ដឹងធ្លាក់ឯណាអត់ដឹង។

កះភ័យណាស់មីងណេះ?

ខះភ័យឡើងរត់ឡើងអង្គរ។

កះអារម្មណ៍ម៉េចដែរមីងពេលហ្នឹង?

ខះមិនមែនថាមិនធ្លាក់ទេ ម្តងធ្លាក់ក្នុងវត្តជើង ។កះចំ!!!ខះប៉ុន្តែមិនដឹងថាធ្លាក់ឯណាទេញ៉ុមនៅ តូចដែរណាស់កូនក្មេងជិះកង់កូនក្មេងទូចៗយើងមិនជិះកង់លេងហេ៎!!ដល់ពេលធ្លាក់ទៅអាច

ត្រូវកូនចិនកាលនោះនៅទូចៗធ្លាក់ទៅក៏ឃើញតែវាខ្ទាត់ទៅជាប់នឹងចុងដើមពោធិ៍។ក៖អូយ!!! ខ៖គ្រាន់តែញ៉ុមនៅទូចៗដែរមិនដែលបានចាប់អារម្មណ៍ហ៎ា!!!!

ក៖ហើយស្លាប់ទេ ខ្ទាត់ទៅហ្នឹង?

ខ៖ស្លាប់ណ៎ា!!ដែររស់!!!ចាំស្លាប់បាត់ទៅណាស់!!កូនក្មេងដូចគ្នា។

ក៖មានដាច់ខ្លួនដាច់អីទេ?

ខ៖ចាំវាដាច់ទៅខ្ទាត់ជាប់ប៉ុន្តែមិនដឹងថានៅតួចចឹងធ្លាក់ទៅទីណាអីទីណីអត់ដឹងទេចាំ គេថានៅវត្តឯងជើង ញ៉ុមនៅវត្តឯត្បូងនេះវត្តឯជើង។

ក៖ចាំហ្នឹងហើយ។ចឹងចាំពីជំនាន់យាយវាដូចតែប៉ុណ្ណឹងមីងណេះ?

ខ៖ចាំ!!!ជំនាន់ដល់ពេលប្រវត្តិយាយញ៉ុមពីជំនាន់នេះអីញ៉ុមអត់ដឹងទេ ញ៉ុមដឹងត្រឹមតែញ៉ុមមកហ្នឹងឯង។

ក៖ចឹងដល់ជីដូនជីតាខាងឪពុកមីងវិញម្តង មិញខាងម្តាយមីងណោះ?

ខ៖ចាំ!!!

ក៖ចុះឥឡូវខាងឪពុកវិញមីង ចុះគាត់ឈ្មោះតាអីយាយអីដែរ?

ខ៖អត់ដែរស្គាល់ព្រោះអីតាញ៉ុមស្លាប់តាំងពីញ៉ុមមិនទាន់កើតយ៉ាង!!!អុះមិនទាន់កើតអីតាញ៉ុមស្លាប់តាំងពីរញ៉ុមនៅក្មេង ចាំស្លាប់តាំងពីម៉ែញ៉ុមមិនទាន់បានប្តីទៅណាស់!!

ក៖ហើយយាយ ម្តាយរបស់មីងហ៎ាមានប្រាប់ថាតាឈ្មោះអីអត់?

ខ៖អត់ ញ៉ុមអត់ស្គាល់ទេ ខ្សែខាងគាត់ញ៉ុមស្គាល់តែតាឡុន ដល់បងប្អូនតានោះញ៉ុមអត់ស្គាល់សោះ។

ក៖ឪពុករបស់ម្តាយរបស់មីងឈ្មោះតាឡុនអើរបស់ប៉ារបស់មីងហ៎ា?

ខ៖អានោះត្រូវជាមាគាត់ទេតាឡុនហ្ន៎ ត្រូវជាជីដូនមួយនឹងគាត់ចាំ!!!ក៖ចាំ!!ខ៖ត្រូវជាជីដូនមួយ

ក៖ជីដូនមួយរបស់តារបស់មីងហ្នឹង?

ខ៖ចាំ!!!

ក៖ហ្នឹងហើយចុះយាយចាំទេ?

ខ៖អត់អត់ចាំ។

ក៖ចាំ!!!ហ្នឹងហើយអត់អីចឹងមីងសំរាប់ជីវិតរបស់មីងហ៎ា!!!មីងកើតទាន់ជំនាន់សង្គ្រាមទាំងអស់មែនទេ លន់ នល់ ប៉ុល ពតអីទាំងអស់ហ៎ា?

ខៈចា៎!!!!

កៈគឡូវទុកប៉ុល ពតវិញនិយាយពីជំនាន់លន់ នល់សិន តើមីងបានជួបរឿងអីគេខ្លះជំនាន់លន់នល់ហ៎ា?

ខៈញ៉ុមជំនាន់លន់ នល់ញ៉ុមណៃទាន់ណៃម៉ែគាត់ គាត់នាំរត់ដែលគេទំលាក់គ្រាប់ គេនាំរត់កាត់ដុប ពួនពេញតែដុប ដល់ពេញយើងរត់ពីនេះ យើងរត់ពីនេះឯង ពីនេះទៅនៅផ្ទះដែលញ៉ុមនៅសព្វថ្ងៃកាលហ្នឹងនៅសុទ្ធតែព្រៃហ៎ា!!!!

កៈចា៎!!!ចឹងរត់ពីគ្រពាំងសេះទៅភូមិវាល?

ខៈចា៎រត់ដែលញ៉ុមនៅសព្វថ្ងៃភូមិវាលប៉ុន្តែយើងនៅភូមិសេរី ប៉ុន្តែសេរីយើងអត់មានភូមិទេណាស់!!!ប៉ុន្តែយើងគេហៅថាភូមិសេរី ដល់ភូមិគេមានតែភូមិវាលទេ ដល់ញ៉ុមរត់ពីនេះទៅណោះឯងរត់កាត់ដុបដូចថាកប៉ាល់វាទំលាក់នោះ ដល់ពេលឃើញកប៉ាល់ចតម៉ែញ៉ុមប្រានក្បាលក្រាបនឹងដុប។

កៈដុបហ្នឹងម៉េចវិញទៅមីង?

ខៈព្រៃយើង។

កៈព្រៃអាកន្ទបៗហ្នឹងហេ៎?

ខៈចា៎!!ហ្នឹងឯង។

កៈមានចូលក្នុងព្រៃស្អីគេ អាល្ពៅកនោះទេមីង?

ខៈអត់ទេសុទ្ធតែដុបកញ្ចស់ ដីអាដុបកញ្ចស់ហ្នឹងវាអត់សូវខ្ពស់ទេវាលិចក្បាលបាត់នោះ។កៈចា៎ញ៉ុមនៅទូចៗដែរហ្វ៎!!!ដល់ពេលគ្រាប់ឃើញកប៉ាល់ចតឃើញក៏ម៉ែញ៉ុមប្រានអោយក្រាបក្នុងដុបហ្នឹង ដែរហ៊ានដើរតាមវាលអី!!!យើងដើរតាមដុបឈើ ល្បាស់ៗហ្នឹង ខ្លាចគ្រាប់កប៉ាល់ទំលាក់នោះចា៎ញ៉ុមដឹងតែប៉ុណ្ណោះឯង។

កៈចា៎តែពេលហ្នឹងទេហេ ប៉ុណ្ណឹងទេហេ?

ខៈចា៎តែប៉ុណ្ណឹងឯង។

កៈមីងមានដឹងថាដូចជាបងប្អូនជីដូនមួយរឺក៏អ្នកញាតិជិតខាងឬក៏អ្នកណាគេមីងដឹងថាពេលហ្នឹងដែលធ្លាប់អ្នកណាគេត្រូវគ្រាប់អីខ្លះអត់?

ខៈដឹងប៉ុន្តែយើងនៅទូច ដឹងថាត្រូវដែរប៉ុន្តែអត់ ដឹងថាត្រូវរួចគេយកទៅណាទៅណីអត់ដឹងទេ

កៈចា៎!!ខៈចា៎!!មានត្រូវជិតផ្ទះដែរ ប៉ុន្តែនៅទូចដែរដូចថាក្មេងដែលទាន់ចេះគិតអី អាយុ៦ ៧ឆ្នាំ កៈចា៎!!ខៈដឹងតែថាត្រូវក៏ត្រូវទៅណាស់!!!

កៈហ្នឹងហើយ។

ខៈមិនដែលបានទៅមើលទៅអីទេអត់។

កៈចឹងមីងមានដែលឮសំលេងរហូតម៉ងហេពេលហ្នឹង?

ខៈលឺសំលេងគ្រាប់កប៉ាល់។

កៈប៉ុន្មានថ្ងៃ?

ខៈប្រហែល២ ៣ថ្ងៃជាប់ទៅណាស់!!!វាមិនជាប់រាល់ថ្ងៃទេ បើសម័យអាពតបានសង្គ្រាមជាប់ចង់កន្លះខែអីណោះក៏មានដែរ!!!

កៈឥឡូវនិយាយពីសម័យប៉ុល ពតវិញវាម៉េចវិញ?

ខៈសម័យអាពតអាដែលមិនទាន់ចប់សង្គ្រាមនោះ វាអត់មានគ្រាប់កាំភ្លើងទេ ដែលយើងគេកំពុងតែជ្រួលច្របល់ អត់មានគ្រាប់កាំភ្លើងទេ!! ដល់គ្រាប់កាំភ្លើងអាយើងសម័យនេះ អាយួនចូលហ្នឹងចាំសម័យយួនចូលហើយបានគ្រាប់កាំភ្លើង អាពតវាមកវ៉ៃនោះ!!កៈចាំ!!!ខៈដល់ពេលអាពតមកវ៉ៃម៉េញ៉ុមតែម៉ោង៣ ដាំបាយហើយ ម៉ោង៣ដាំបាយ ពួកញ៉ុមមកពីធ្វើការម៉ោង៥អោយដួសបាយហូបតែមិនឆាប់ហូបបាយច្បាស់ជាអត់បាយហើយ។កៈចាំ!!!ខៈចុះវាបាញ់ដូចថាវាចូលដល់កន្លែងដូចថាមានយួន ដូចថាទាហាននៅអញ្ចេះៗណាស់!!!វានៅក្នុងដុបមិនបានអីវាបាញ់សាញ់យើង៣គ្រាប់ វាសាញ់អោយយើងចុះក្រាបនៅក្នុងអន្លង់ហា!!អាពតវាសាញ់អោយខ្មែរចុះចូលក្នុងអន្លង់ហា!!!

កៈចាំ!!ដើម្បីវាបាញ់យួន។

ខៈបាញ់យួន លឺអាគ្រាប់កាំភ្លើងប៉ាក់ពុងៗលឺគ្រាប់ហើយព្រៃររកអន្លង់អោយហើយទៅ!!!បានអីដូចថាវាមកបាញ់កន្លែងយួនវាដាក់៤ ៥គ្រាប់ក៏វាទៅបាត់ទៅណាស់!!!

កៈហ៊ុំហើយស្លាប់យួនទៅ?

ខៈអាខ្លះក៏ងាប់អាខ្លះក៏របួសរត់សែងគ្នា របួសទៅណាស់ ។កៈហ្ហ៎!!ខៈចុះឯង។

កៈចឹងនៅខាងមុខអង្គរបាញ់គ្នាច្រើនមីងហេ៎?

ខៈហេអង្កាល់ដែលញ៉ុមមកដាច់ចូល៨០(១៩៨០)ហើយហ្នឹងនោះអង្កាល់អាឆ្នាំ៧៩(១៩៧៩) ដែលញ៉ុមអត់ទាត់បានមកណោះទេ ញ៉ុមនៅស្រុកគេ កាលសម័យអាពតញ៉ុមនៅស្រុកគេតើ។

កៈស្រុកអីគេវិញមីង?

ខៈនៅសម្បត្តិសំរោងយើងឯកើតនេះ!!!!

កៈចាំនៅខេត្តសៀមរាបហ្នឹងដែរ?

ខៈខេត្តសៀមរាបដែរ។

កៈតែស្រុកមិនមែននៅនេះទេ?

ខះមិនមែនទេ ប៉ុន្តែញ៉ុមទឹមតែមកណោះដែរ៨០(១៩៨០)បានញ៉ុមចូលមកនេះ។កះចំា!!ខះចំា!

កះឥឡូវមីងអាចប្រាប់ញ៉ុមពីថ្ងៃដំបូងពេលដែលប៉ុល ពតចូលហើយម៉េចដែរជីវិតរបស់មីងហ៎ា តើវាយ៉ាងម៉េចទៅតើពីថ្ងៃដំបូងសកម្មភាពអីវ៉ាន់ខ្លះដើម្បីអោយវាមាននូវបង្អត់អាហារ ក៏ដូចជាបាញ់សម្លាប់ អោយធ្វើការជាទម្ងន់ហ៎ា?

ខះប៉ុនសម័យអាពតនោះ ប៉ុនយើងអត់បាយអត់មែន គេអត់ធ្វើបាបទេក្រមាណាស់ ពេលក្រោកឡើងគេអោយហូប អោយហូបតែបបរអត់មានអីទេ មានតែបបរហើយនឹងអំបិល បបរគេដាក់អំបិលអោយយើងមួយចឹបៗចំាញ៉ុមជួបពាម៉ាញ៉ុមជំដែងមកជំនាន់អាពតពាឆ្នាំហ្នឹងហ៎ា!!បបរកំពីងចេកម្តង។

កះកំពីងចេក?

ខះកំពីងចេកយើងនេះណាស់អាគល់ចេកនេះណាស់!!!

កះហ្នឹងហើយ។

ខះគល់ចេកម្តងដើមចេកម្តងអាដំឡូងម្តងអាបបររាវអាទឹកខ្លួកហ្នឹងហ៎ា!!!អានេះជិតចប់ហើយ អាបបរទឹកខ្លួក ដូចថាមួយការដូសមកតែទឹកទទេ គ្រាប់អង្ករប្រហែលបានមួយរែកប៉ុននេះឯងចំា!!!សុទ្ធតែទឹក បើអាបបរដើមចេកញ៉ុមហ្វំវេទនាណាស់!!!ដើមចេកមិនមែនហាន់ដូចទីនេះទេណាស់!!បុក គេហាន់ដើមចេករួចបុកដូចបាយជ្រូកចឹងណាស់!!!ទៅបបរទៅ ឃើញអង្ករមួយគ្រាប់ៗទៅហុតគ្រូកៗទៅចត់ៗអត់មានអំបិលមានអីទេសាបឈឹង។

កះអើពិបាកលេបងាប់ហើយមីង!!!

ខះចំាអត់មានអំបិលទេញ៉ុមជួប ជួបពាដងនៅសម័យអាពតហ្នឹងហ៎ា!!កះចំា!!ខះមែនជួបពាដងមួយថ្ងៃអីទេណាស់ វាជួបចូលខ្ទង់មួយខែអីណោះ!!!

កះគ្រាន់ហូបអាហ្នឹងហេ៎?

ខះចំា!!គ្រាន់ហូបអាហ្នឹង បើសិនណាអាកំពីងចេកវិញញ៉ុមប្រាប់ទៅដែលប្អូនញ៉ុមនៅទូចនោះ ប្អូនញ៉ុមអានោះអាយុពៅគេប្រហែលជាអាយុ១ខួបជាង ញ៉ុមមកដល់ញ៉ុមរើសអាមួយនោះអាយុប្រហែលជា៣ ៤ឆ្នាំ អាបន្ទាប់ញ៉ុមណាស់!!ញ៉ុមរើសយកតែកំពីងចេកស៊ីខ្លួនឯង គេវាល់អោយនោះ កំពីងចេកស៊ីខ្លួនឯងអាណាអង្ករអោយប្អូនណាស់!!!ទាល់យប់ឡើងនេះពោះដុំប៉ុនៗនេះ!!!ចុះវាកូរនោះ ដូចថាវាក្រពះកិននោះវារមូល។

កះឈឺណាស់មីងណេះ?

ខះវាអត់ឈឺទេដូចថាវាកង ដូចថាវារមូលហ៎ា!! ចំាវាដុំឡើងប៉ុនៗនេះទៅណាស់!!ដុំពោះយើង!!

កះហ្នឹងហើយ។ខះចំា!!!កះលេបចេកហ្នឹងទៅ។

ខះចំាចត់នោះឯងចុះមានអីមានតែកំពីងចេកបបរទៅក៏ទឹកខ្មៅទៅ។

ក៖ចាំអូយ ហើយចុះម្ដូបពេលហ្នឹងវាសំបូរទេមីងពេលហ្នឹង ការដាំដុះអីវ៉ាន់បន្លែផ្លែឈើអីច្រើនទេ?

ខ៖គេអត់អោយដាំផង ដូចថាយើងដាំបានមានតែដាក់រួម គេអត់អោយយើងដាំតែម្ដង !!!

ក៖ចុះបើដាំរួមបានហូបអត់ចុះ?

ខ៖បើរួមមិនបានហូបទេបានថាគេអ្នកចល័តដូចថាញ៉ុមដាំត្រកួននេះណាស់!!យើងបានហូបតែបន្លែអីៗផ្សេងទេដូចថាត្រកួនតែដុះវែងមកកាត់ទៅកន្លែងចល័តអស់។

ក៖យកទៅអោយអ្នកណាគេហូបវិញ?

ខ៖អោយដូចអ្នកណាគេដែលចាស់ៗធ្វើការហ្នឹង។ពួកញ៉ុមនៅនោះហូបបន្លែផ្សេងៗទៀត។

ក៖តែដូចឮអ្នកចាស់ៗហ្នឹងអត់មានអីហូបដែរហ្នឹង។

ខ៖អត់ដូចគ្នាប៉ុន្ដែដូចថាគេចេញកម្លាំងពលកម្មអញ្ចេះគេមានបាយហូបណាស់!!!គេអ្នកធ្វើការធ្ងន់គេមានបាយហូប ដល់ពួកយើងកុមារអត់ អត់បាយដែលយើងអត់ឃ្លានបាយអត់បានចេញពលកម្មនឹងគេហ្នឹង។ក៖ចាំ!!ខ៖ចាំ!!!

ក៖ហើយចុះមីងអើយពេលអាថ្ងៃដំបូងហ៎ា!!ម៉េចបានដឹងថាប៉ុល ពតមាន?វាម៉េចទៅ?

ខ៖ញ៉ុមអត់ដឹងទេ
ថាពេលវាដំបូងចាប់ពីមុនដំបូងបង្អស់ញ៉ុមដឹងប៉ុន្ដែមិនដឹងថាមូលហេតុអីទេ ណាស់!!

ក៖ហ្នឹងហើយ។

ខ៖មុនដំបូងកប៉ាល់ កប៉ាល់ដំបូងគេហៅអា៥២ណាស់!!!វាហោះ វាហោះទៅក៏នាំគ្នារត់។ក៖ចាំ
ខ៖នាំគ្នារត់ទៅក្នុងដុបណាស់ រត់ទៅក្នុងដុបក៏អង្ករគេបើកអោយ កាលនោះណាស់!! បើកអោយអង្ករសំរូបយើងអង្ករមួយគ្រាប់ៗញ៉ុមដឹងតើ
ប៉ុន្ដែអត់ដឹងថាមូលហេតុអីក៏មិនដឹងទេដឹងតែគេ បើកអង្ករអោយហ្នឹង
គេបើកអង្ករអោយគេចែកសាច់ជ្រូកអោយហ្នឹងកាលនោះណាស់ នឹងកាលមុនដំបូង
ដល់ពេលចប់ពេលនោះហើយមកនៅនេះហ៎ាចេញមកនៅក្នុងភូមិយើងវិញ
ចេញមកនៅវិញមានសហករណ៍បណ្ដោយពេលនេះគេមានសហករណ៍គេមួយក្រុមចឹងប៉ុន្មាន
បួនដប់ម្ភៃគ្រួសារអញ្ចេះគេដាំបាយអោយយើងទៅចេះទៅណាស់!!!ដាំបាយថ្ងៃអត់សេដ្ឋកិច្ច
ស្ងោរដំឡូង ស្ងោរដំឡូងហូបទទេ ចាំចុះឯងដល់ពេលចប់អានោះទៅបានចូលសហករណ៍អំនោះឯង។

ក៖ចាំហ្នឹងហើយចឹងពេលមីងពេលជំនាន់ប៉ុល ពតដំបូងហ្នឹងអ្នកមីងនៅភូមិត្រពាំងសេះហ្នឹងហេ?

ខ៖ណោះញ៉ុមនៅស្រុកគេ។

ក៖គេជំលៀសមកឯណាវិញ?

ខៈជំលៀសពីនេះទៅនៅនោះ។

កៈជំលៀសអាពីស្រុកគេនោះមកនៅនេះវិញ?

ខៈទេអត់ទេណាស់!!យើងជំលៀសអាអង្កាល់នេះអាប្រហែលជំនាន់លន់ នល់ចឹងវិញដែលយើងជំលៀសពីនេះទៅនៅនោះវិញទាំងអស់វិញ។កៈហ្ហ៎!!ខៈចាំ!!ពេលទៅនោះរួចទៅដល់ណោះទៅដល់នោះអោយបានមួយឆ្នាំបានចូលអាពត។កៈចាំ!!ខៈបានប្រហែលមួយឆ្នាំនឹងឯងបានចូលអាពត។

កៈចុះពួកទាហានលន់ នល់បាត់ទៅណាអស់ទៅ?

ខៈញ៉ុមអត់ដឹងដែរ។

កៈបាត់អស់អាលីងម៉ង?

ខៈដឹងទៅណ៎ាអស់ដឹងផងយើងនៅទូច។

កៈគន្លងរមិញការហូបចុកហើយអស់ហើយមីងហេ?ខៈចាំ!!!កៈគន្លងសំរាប់ជីវិតដែរមីងឃើញ ផ្ទាល់ធ្លាប់ឃើញអ្នកណាគេយកគេទៅសម្លាប់ឬក៏ ឃើញអ្នកណាគេកាប់សម្លាប់ម៉េចខ្លះទេមីង ?

ខៈញ៉ុមអត់បានឃើញគេសម្លាប់ម៉េចទេ ឃើញតែត្រឹមគេចង។

កៈម៉េចបានចឹងមីង ?

ខៈឃើញគេចាប់ចង ឃើញគេចង គេចងដោះខោអាវនៅតែខោខ្លី គេចងភ្ជាប់គ្នា៤ ៥នាក់អញ្ចេះក៏ដើរទៅ ដូចថាដើរដង្ហែរគ្នា៤ ៥នាក់អញ្ចេះថាហ្អែងដើរអោយលឿន ដូចជាក់អានេះមួយដួលទៅទាំងអស់គ្នាហ្នឹង ចុះបើខ្សែចងភ្ជាប់គ្នានោះ ចាំ!!បើយើងអត់ហ៊ានមើលទេ យើងមើលឃើញតែមួយភ្នែកហ្នឹងអត់ហ៊ានមើលទេ។

កៈដើរនៅមុខយើងហ្នឹងហេ៎?

ខៈចាំ។

កៈនៅមុខមនុស្សទាំងអស់ហ្នឹងហេ?

ខៈដូចថាគេដើរតាមផ្លូវនេះណាស់ឪញ៉ុមអត់អោយមើលទេគាត់កាលឪញ៉ុមទាន់ដាប់គាត់អោយតែម៉ែមើលទេរូបយើងក៏ដូចរូបគេដែរគាត់ថាអញ្ចេះចាំញ៉ុមឃើញម្តងដល់ពេលញ៉ុមដើរទៅញ៉ុមទៅរកដូរអង្ករគេណាស់!!!ញ៉ុមទៅដូរអង្ករគេស្រុកត្រពាំងផ្លុងយើងហ្នឹងប៉ាយើងសព្វថ្ងៃអីលើដំដែកទៀតណាស់!!!កៈចាំ!!!ខៈទៅក៏ឃើញគេចងបណ្តើរទៀតណោះនៅក្នុងដុកគេបណ្តើរមកពីក្នុងភូមិមកក្នុងដុកមកវ៉ៃចោលប៉ុន្តែគេវ៉ៃចោលណាអត់ដឹងទេ។

កៈតែមីងដឹងមូលអីអត់ដែលគេវ៉ៃហ្នឹង?

ខៈអត់ដឹងទេភូមិខុសគ្នាឃើញតែគេបន្តើរទៅចាស់ៗថាដែលឃើញប៉ុណ្ណោះហើយដែលរស់ទេ គេយកមកវ៉ៃចោលទីនេះឯងចង ចងភ្ជាប់គ្នាហ្នឹង មានទៅខុសប្លែកអី។

ក៖ចាំហ្នឹងហើយ។

ខ៖ញ៉ុមជួបតែ២ដងប៉ុណ្ណឹងឯង។

ក៖ចាំចឹងពេលហ្នឹងឪពុករបស់អ្នកមីងស្លាប់នៅក្នុងជំនាន់ហ្នឹង មែនទេ។

ខ៖ស្លាប់ជំនាន់នោះឯងឪញ៉ុម ស្លាប់បានប្រហែលជាជាងមួយឆ្នាំ។ក៖ចាំ!!!ខ៖បានចប់សង្គ្រាម

ក៖ចឹងបងប្អូនអ្នកមីងមានប៉ុន្មាននាក់វិញ?បងប្អូនប្រុសស្រីហ៎ា?

ខ៖៦។

ក៖៦នាក់ដែរ?មិនមែនកូនបងប្អូនហ៎ា?

ខ៖បងប្អូន។

ក៖៦ដែរ។ហើយស្រីប៉ុន្មានប្រុសប៉ុន្មាន។

ខ៖ហ្នំបងប្អូនញ៉ុម៦នាក់ជំនាន់អាពត ៥ទេ ច្រលំអាកូនប្ដីក្រោយ។

ក៖អត់ទេអោយតែនេះ បងប្អូនរួមសាច់ឪពុកម្ដាយម៉ងហ៎ា??

ខ៖ណែបើសម័យអាពតនោះដែលម៉ែញ៉ុមអត់ទាន់បានប្ដីនោះ។ក៖ចាំ!!!ខ៖មានតែបងប្អូនមុន ៥នាក់ទេ។

ក៖៥នាក់ ចុះដល់ពេលក្រោយទៀត?

ខ៖ក្រោយទៀតគាត់ជិតចប់អាពតហើយម៉ែញ៉ុមសែន គេចូលសួរម៉ែញ៉ុមសែន ខែកក្កិកឡើងមាឃធំឡើង ខែនោះណ៎ា!!!ខែយើងហៅខែមាឃធំហ៎ាគេដាច់ទៅក៏យួនចូលម៉ែញ៉ុមសែនខែកក្កិកខែមាឃធំយួនចូលបានកូន៣សព្វថ្ងៃ។ក៖ចាំ!!!ខ៖ទៅបានប្ដីក្រោយនេះបានកូន៣ប្ដីគាត់ងាប់ចោលទៀត។

ក៖ហើយគាត់អត់មានយកប្ដីទៀតណាហី?

ខ៖គាត់ចាស់ហើយ។

ក៖គាត់មានតែ២នាក់ហ្នឹងទេ?ខ៖ចាំ!!!ក៖ហើយចឹងអើបងប្អូនមីង មីងជាកូនទីប៉ុន្មានវិញ?ឪពុកមុន?

ខ៖ឪពុកមុនញ៉ុមកូនទី៣។

ក៖ទី៣?ខ៖ចាំ!!ក៖ហើយឥឡូវបងប្អូនអ្នកមីងគាត់នៅរស់ទាំងអស់ឬមួយក៏គាត់ស្លាប់ខ្លះ អនិច្ចាកម្ម?

ខ៖នៅរស់ទាំងអស់ៗ ទាំងមុនទាំងក្រោយ។

ក៖ឥឡូវគាត់នៅសៀមរាបហ្នឹងឬក៏គាត់ទៅទីណាណីខ្លះ?

ខ៖នៅជុំគ្នាទាំងអស់នេះ។

ក៖សៀមរាបនេះទាំងអស់ ហ្នឹងហើយ។

ខ៖ចុះរាល់ថ្ងៃជួបជុំបងប្អូនជិតៗផ្ទះនោះ៣ ៤នាក់។

ក៖អ៊ីនៅភូមិវាលហ្នឹង?

ខ៖ចាំនៅជុំគ្នាទាំងអស់។

ក៖ចាំហើយពួកគាត់ម៉េចដែរហើយជីវភាពការរស់នៅរបស់គាត់ម៉េចដែរ?

ខ៖គេពួកគេនោះមាភ្នំគេមិនដូចញ៉ុមទេ
ថាគេទៅគេម៉ាភ្នំតែម្តងគេវាមិននឿយហត់ដូចញ៉ុមហ៎ា
នោះបើថាគេហូបចុកក៏គេមិនសូវដូចយើងហ៎ា។ក៖ចាំ!!ខ៖ដូចថាគេមានកូនទៅកូនគេពឹងបាន
ដល់តែពេលញ៉ុមនោះមានកូនធំហើយពឹងវាមិនបានទៀតហ៎ា!!

ក៖ហ្នឹងហើយ។

ខ៖វាពិបាកបានថា។

ក៖ចាំចឹងអ្នកមីងចូលដល់នេះវិញម្តងប្រហែលជាបន្តិទៀតកូនរបស់អ្នកមីងវិញតើអ្នកមីងមាន
បានអោយកូនៗទៅរៀនទាំងអស់អត់?

ខ៖ញ៉ុមអោយរៀនទាំងអស់កូនញ៉ុម ប៉ុន្តែអាបងអត់កើត។

ក៖អត់រៀនម៉ង។

ខ៖ចាំ។ ទាំងអស់ មីនេះរៀនបានថ្នាក់ទី៧ឈប់ ដូចគេតំរូវលុយណាស់ គេតំរូវយកលុយប៉ុន នេះ
ប៉ុណ្ណោះទៅក៏វាអត់មានលុយអោយកូនរៀនហ្ន៎។ក៖ចាំ!!ខ៖ទៅវាឈប់ដោយខ្លួនវាចាំ។

ក៖ហ្នឹងហើយ។

ខ៖ដល់ពេលមីងបងទៀតឮគេថាយកលុយ៣០០០០ឈប់មុន ឈប់មុនពេលគេយកលុយ។

ក៖ពេលហ្នឹងឆ្នាំប៉ុន្មានបានគាត់ឈប់ហ្នឹង?

ខ៖ឈប់នេះមិនដឹងកាលឆ្នាំប៉ុន្មានទេ បើឡើង ៣ ៤ ៤ឆ្នាំឡើងវាបានប្តីហើយ។

ក៖ហ្ន៎ហ្នឹងហើយ។

ខ៖ឈប់តាំងពីវាអាយុប៉ុន្មាន អាយុ១៣ ១៣ ឡើងសព្វថ្ងៃវាអាយុឡើងចង់៣០ មីនោះឡើង
២៧ហើយ។

ក៖ចឹងមូលហេតុអីបានមីងអោយកូនមីងទៅរៀនហ្នឹង?

ខ៖ចង់អោយកូនចេះ។

ក៖មើលអាខុសពីចេះហ្នឹងស្អីគេទៀតទៅ?មីងគេថាការសិក្សាហ្នឹងវាមានអត្ថន័យយ៉ាងម៉េចដែរសំរាប់មនុស្សទាំងអស់ឬក៏សំរាប់កូនចៅក្រុមគ្រួសារមីងចឹងហ៎ា??

ខ៖ញ៉ុមមិនថានេះទេចង់អោយកូនចេះដើម្បីទៅទីណាដើម្បីងាយស្រួលយើងចេះអក្សរទៅយើងទៅរកការងារអីក៏ស្រួលដែរបានចង់អោយកូនចេះហ្នឹងហ៎ា!!!!ដល់ពេលយើងល្ងង់ទៅសុំការងារគេយើងបានត្រឹមតែការងារកំប៉ិកំប៉ុង ការងារធ្ងន់ចាំដល់ពេលបង្ខំកូនក៏បង្ខំអត់កើតបើកូនវាទៅអត់រួចដែរយើងអត់។

ក៖ចាំហ្នឹងហើយ។

ខ៖បានត្រឹមតែថ្នាក់ទី៣ ទី៤ឈប់អស់ចាំ។

ក៖ហ្នឹងហើយ ចឹងប្រហែលជាកូនចៅជំនាន់ក្រោយអោយរៀនច្រើនបន្ថែមទៀត!!!

ខ៖ចាំបង្ខំកូនវាមិនកើត
បន្ទោសកូនវាមិនកើតបើយើងអត់។ក៖ចាំ!!!ខ៖យើងរកលុយអោយកូន វាមិនបានចាយ។

ក៖ហ្នឹងហើយចាំចឹងអ្នកមីងតើមីងស្រលាញ់ក្រុមគ្រួសារអ្នកមីងខ្លាំងអស់?

ខ៖ញ៉ុមកូនញ៉ុមស្រលាញ់ទាំងអស់។ចាំទោះបីតែញ៉ុមខឹង ក៏ញ៉ុមមិនទាត់ចោលដែរកូន ទោះបីកូនអាក្រក់យ៉ាងណាក៏ញ៉ុមនៅតែស្រលាញ់កូនដែរ។ក៖ចាំ!!!ខ៖ត្បិតតែជេរវាមិនបានក៏នៅតែកូនប៉ុន្តែចេះតែជេរ ជេរទៅ អោយវាតាមវាមិនតាមិនដឹងធ្វើម៉េច។

ក៖ចាំចឹងអ្នកមីង !!!ម៉េចដែរ?

ខ៖កូនញ៉ុមនិយាយអោយត្រង់ទៅតែមួយហ្នឹង!!!

ក៖បងគេអត់?

ខ៖ទេអាទី៣ពិបាកតែមួយហ្នឹង។

ក៖ផ្ទះញ៉ុមពិបាកជាងគេគឺមួយបងហ្នឹងម៉ង។

ខ៖ញ៉ុមអត់ទេ អាបងគេពិបាកដែរ ពិបាកពីក្មេងពេលវានៅទូចៗណាស់!!ពេលវាមិនទាន់ចេះគិតណាស់!!!ដល់ពេលវាចេះគិតចូលអាយុ១៥កូនញ៉ុមណាស់!!!!ចូលអាយុ១៥អាបងគេធ្វើការបំរើញ៉ុមរហូតឡើងបានប្រពន្ធ ដល់អង្កាល់កូនញ៉ុមនៅទូចៗអញ្ចេះណាស់!!ដែលទៅរកអីបានហូប។

ក៖៣ ៤ ឆ្នាំអីចឹងមីងណោះ?

ខៈចាំ៤ឆ្នាំ ៥ឆ្នាំមីបង មីនេះនេះទូចជាងមីអូននេះ មីបន្ទាប់មីបងប៉ុននេះឯង ចុះ៣ ២ "៤ ២ នោះកូនញ៉ុម។

កៈចាំមីងមានកូនភ្លោះអីអត់ចឹង?

ខៈអត់ទេ។

កៈអត់មានកូនភ្លោះអីទេហ៎?ខៈចាំ!!!កៈស្មានតែមានភ្លោះអីទៅ!!!

ខៈអត់មានទេ។

កៈពួកម៉ាក់ញ៉ុមកូនភ្លោះ៣មីង។ខៈចាំ!!កៈតែស្អាតៗណាស់!!ហ្នឹងហើយ។

ខៈកូនញ៉ុមអត់មានស្អាតទេ ចុះម៉ែឪក្រដែរ។

កៈហ៊ីមិនស្រួលស្អាតហ្នឹងមីងចេះតែនិយាយហ្នឹង។

ខៈមែនម៉ែឪក្រកូនក្រដែរហ្នឹង។

កៈចឹងមីងតើធ្វើម៉េចដើម្បីអោយក្រុមគ្រួសារមីងមានសុភមង្គលទៅ មីងធ្វើអីខ្លះ លះបង់អីខ្លះពី គ្រួសារមួយហ្នឹងហ៎??

ខៈហ្ន៎ញ៉ុមមិនដឹងថាធ្វើម៉េចអោយកូនមានសុភមង្គលបើយើងអត់ហ្នឹង ញ៉ុមអប់រំកូនចេះតែអប់ រំចង់អោយតែកូនល្អប៉ុន្តែថាកូនរៀនកាត់កែរដោយសារយើងរកអីមិនបានអោយវាស៊ីចាយអោយវាបានគ្រប់គ្រាន់និងគេបានកូនយើងទៅជាដើរ វាមិនដើរទៅណាពៃលៃពោលោរទេ ថាវាដើរទៅនៅនឹងគេទៅណេះ៤ ១០ថ្ងៃ កន្លះខែណាស់!!១ខែទៅបានវាមកផ្ទះវិញ កាលវានៅទូចណាស់!!នៅប៉ុនៗនេះណាស់!!មានតែមួយប៉ុននោះឯងដល់ផុតពីនោះអត់ទេ!!កៈចាំ!!ខៈនៅជុំតែម៉ែឪទោះបីតែអត់ស៊ីអំបិលប្រហុកយ៉ាងណាមិនទៅណាដែរបើអាមួយនោះដែលញ៉ុមថាធឹកបានហ្នឹងហ៎!!ទៅនៅទីនេះ១០ថ្ងៃទៅនៅទីនោះ១០ថ្ងៃ ទៅនៅនោះ១ខែ២ខែ ញ៉ុមទៅតាមវាមិនមកទេដល់ពេលនេះវាមកខ្លួនវា។

កៈហើយដល់ពេលចឹងបានអីហូបទៅ?

ខៈដូចថាទៅនៅផ្ទះគេទៅជួយធ្វើការងារគេទៅក៏ទៅហូបនឹងគេទៅណាស់!!ចុះឯងមានតែកូនមួយប៉ុណ្ណេះឯងក្រៅពីនោះអត់ទេ។

កៈចាំពិបាកដែរចឹង!!!

ខៈពិបាកហើយយើងជាម៉ែឪធ្វើម៉េចសប្បាយចិត្ត ពិបាកចិត្តមិនដឹងធ្វើម៉េចយើងទៅតាមយើង ដូចថាយើងស្រណោះកូនទៅហៅកូនហើយកូនមិនមកទៀតបើថាវារត់ទៅនៅនឹងគេទៅស៊ីអ្នកមានស៊ីចុកទៅគ្រាន់ ទៅនៅអានឹងគេនោះក្រជាងម៉ែឪទៀត គ្នារកអង្ករគីឡូស៊ីមិនបានទៅនៅជាមួយគេគ្នាក៏ប៉ុន្តែថាដូចថាអ្នកក្រយើងវាចិត្តបានចឹងហ៎!!!ទោះបីក្រតែរូបទេបានមកស៊ី

ទាំងអស់គ្នាចំា។កះចំា!!ខះដូចតែកូនវាដែរ!!ដូចកូនវាដែរ។កះចំា!!!ខះបានមកស៊ីទាំងអស់គ្នាជុំមិនថាបានមកហើយហ្អែងទៅផ្ទះទៅ អត់ទេបានមកក៏នាំគ្នាដាំស៊ីដូចបងប្អូនទៅណាស់!!!

កះហ្នឹងហើយ។

ខះញ៉ុមស្រណោះនឹកឃើញថាវាអត់ដែលទៅតាមមកវិញ កូនណ្ហើយកូនឯងមកនៅធ្វើអញ្ចេះមើលមានអីស៊ី ស្រណោះគ្នាវាអត់មកទេ ដល់ពេលមក មកខ្លួនវា ឯងទៅតាមអត់មកសោះ។

កះចោលម៉េចកើតមីងហ៎?

ខះចំា!!

កះដូចថាពិបាកហើយរកម៉ែរកឪ។

ខះចំានោះឯង ដល់ពេលមក មកខ្លួនវា ហើយឯងបង្គាប់កូនហើយ ពូវារៀនជាងម៉ូតូលើកមុនហ៎ា!!ថាអូនណ្ហើយទៅរៀនជាងម៉ូតូជាមួយពូទៅកូនក្រែងអនាគតទៅកូនឯងពិបាកដើរធ្វើការងារអោយគេហ៊ីប្រលាក់ដៃ។កះហ៊ឺ!!ខះនេះបានថាក្មេងវាឆោតពូខ្លួនឯងសោះគ្រាន់ទៅរៀនសោះពិបាកអស់លុយហ៎!!!គេដែលយកលុយហ៎អោយតែយើងទៅរៀននិងគេ អត់វាអត់គិតកះចំាពិបាក។

ខះហ្នឹងហើយ។

កះចឹងមីងតើមីងមានដំបូន្មានអីខ្លះដើម្បីផ្តែផ្តាំ
អើដូចជាប្រដៅកូនចៅហ៎ាតើប្រដៅគាត់អោយ ធ្វើម៉េចខ្លះទៅ?

ខះញ៉ុមមិនសូវចេះប្រដៅដែរកូនប៉ុន្តែញ៉ុមគ្រាន់តែប្រដៅថាទៅណាអោយចេះចាស់ទុំស្រណោះអានិត ភ្លើតភ្លើនញ៉ុមចេះតែប៉ុណ្ណឹង មិនដែលចេះប្រដៅកូនថាម៉េចផង។កះចំា!!ខះចំាគ្រាន់តែណែនាំវាថាកូនឯងទៅណាអោយមនុស្សចាស់ស្រណោះអានិតកុំដើរភ្លើតភ្លើន ។

កះហ្នឹងហើយចំា!!!

ខះមានតែពាក្យណែនាំប៉ុណ្ណឹង។ខះចំា!!កះចុះមីងដែលមានបងប្អូនឬក៏ឪពុកម្តាយឬក៏ដូនតាឬក៏កូនចៅមីងធ្លាប់មានអ្នកណាគេទៅរស់នៅស្រុកក្រៅឬក៏មានទៅអាមេរិច ទៅថៃ ទៅវៀតណាមទៅអឺរ៉ុបអីវ៉ាន់អត់?

ខះអត់សោះ។

កះនៅតែក្នុងស្រុកខ្មែរយើង?

ខះចំា!!ស្រុកខ្មែរយើង។កះចំា!!!ខះដែលបានចេញទៅណាទេ!!!បងប្អូនញ៉ុមកំសត់ទាំងអស់គ្នាគិតទៅម៉ាពោះម៉ែញ៉ុមដូចថាគេមានស៊ីចុកគ្រប់គ្រាន់ប៉ុនថារឿងរៀនអីអត់បានអ្នកណាចេះអីមួយទេចំាទាបបំផុតបងប្អូនញ៉ុម។

កះដោយសារសង្គ្រាមដោយសារអីម៉េចបានជាចឹងមីង?

ខះអត់មានដោយសារសង្គ្រាមទេ ចប់អាពតអស់ហើយដែលយើងរៀននោះណាស់!!!ប៉ុន្តែថា យើងក្រុមគ្រួសារយើងដូចថាយើងខ្វះណាស់!!!វាខ្វះអត់មានអីហូបចុកទៅម៉ែឪគាត់មិនពិបាក ចិត្តហេ៎?ហ៊ីកូនល្ហើយកូនឯងមិនបាច់រៀនច្រើនឡើងថ្នាក់យូរអី កូនល្ហើយម៉ែឪពិបាកយ៉ាង នេះជួយការងារម៉ែឪចេះចុះយើងលែងរៀនចូលបាត់ហើយចាំយើងអាលែងតែស្រណោះម៉ែដែលគាត់និយាយចុះយើងមិនស្រណោះគាត់។

កះហើយឃើញពិបាកនឹងភ្នែកផងមីងណោះ?

ខះហ្នឹងឯងឃើញពិបាកគាត់អត់លុយចាយអីផងស្រណោះគាត់យើងដែលរៀនបានចូល។

កះចាំ!!ខះចាំហើយណាមួយការងារផ្ទះទៅវាដើរមើលគោមើលអីទៅណាស់!!!ប្អូនញ៉ុមណាស់ កាលហ្នឹងមានគោមានអីនៅ ដែលញ៉ុមមិនថាញ៉ុមមួយជីវិតនេះញ៉ុមវេទនា តាំងពីរញ៉ុមក្មេងរហូតដល់ញ៉ុមចាស់ឥឡូវ។កះចាំ!!ខះតាំងពីញ៉ុមមានប្តី ប្តីអោយនៅផ្ទះក៏ញ៉ុមអត់ចេះនៅផ្ទះ ដែរ។

កះមីងធ្វើអីគេទៅ?

ខះធ្វើស្រែចេះឯង!!កះចាំ!!ខះខែស្រែញ៉ុមធ្វើស្រែចេះឯង ធ្វើស្រែគេថាហ៊ើយឯងមិនបាច់ទៅទេនៅផ្ទះមើលកូន មិនដែលនៅទេញ៉ុមអត់ចេះនៅតែម្តង ទៅពារកូនទៅនឹងគេដែរទៅណាស់!! ដាក់កូនពេញតែវាលស្រែ គឺអត់ចេះនៅតែម្តងមួយជីវិតនេះបើថាញ៉ុមទៅចំការចេះក្រោកមក ដឹងតែការងារ យើងដឹងថាមកផ្ទះអញ្ចេះ អត់អីហូបចុះឯងក៏អញ្ចេះឯងញ៉ុមដើររកចេះឯង តែមកដល់ប៉ុននោះញ៉ុមមកដល់ផ្ទះបាន៣ថ្ងៃទៅមួយអាទិត្យហ្នឹង ហ៊ីអញមិនដែល គេអ្នកជិតខាងមិនដែលឃើញមីនេះអង្គុយនៅផ្ទះថាបានយូរនឹងគេសោះតែមកដល់!!!

កះគេថារពឹសដៃផ្ទៃឆ្អែតមីងហេ?

ខះចាំតែមកដល់ផ្ទះឃើញ២ ៣ថ្ងៃឃើញតែចេញលក់ហើយ ញ៉ុមមិនដែលចេះនៅស្ងៀមនឹង គេទេ។

កះហ្នឹងហើយ។

ខះប៉ុន្តែវាមិនបានច្រើនបានតែមួយហូបៗហ្នឹងឯង។កះចាំ!!!ខះចាំបានតែមួយចាយៗ។

កះហ្នឹងហើយ។

ខះបើយើងអត់រកក៏អត់ទៅ។

កះចឹងអ្នកមីងសំរាប់ឥឡូវអ្នកមីងដូចជា៥៣ឆ្នាំហើយអ្នកមីងណោះ?ខះចាំ!!!កះចឹងសំរាប់គំរោងការនៃជីវិតរបស់មីងគិតថាពេលថ្ងៃអនាគតទៅមានគិតថាមានចង់ធ្វើអីបន្ថែមទៀតសំរាប់ ជីវិតអីអត់?

ខះញ៉ុមរាល់ថ្ងៃ។

កះចាំមានគំរោងអីអត់?

ខះញ៉ុម ញ៉ុមមានគំនិតដែរប៉ុន្តែមិនដឹងថាយើងធ្វើកើតក៏អត់!!

ក៖ឥឡូវគំនិតអីគេវិញ?

ខ៖គំនិតញ៉ុមចង់តែរកស៊ីដូចគេអញ្ចេក។

ក៖រកស៊ីអីគេវិញ?

ខ៖រកស៊ីយើងលក់របស់របរអីដូចគេមាន់អាំងមាន់អី។ក៖ចាំ!!!ខ៖ហើយបើចិត្តញ៉ុមវិញញ៉ុមអត់ចង់ទេថាដូចចុះចង់ប្រគល់កូនរកស៊ីណាស់!!ក៖ចាំ!!ខ៖បើសិនចិត្តញ៉ុម ញ៉ុមចង់តែលក់នំបញ្ចុកអីដែលយើងចាស់ហើយណាស់!!ក៖ចាំ!!ខ៖ចាំចង់លក់ចុះៗឯងដូចថា!!

ក៖មិនព្រមលក់ទៅ ចាំបាច់មានគំរោងអីលក់ម៉ងទៅ!!

ខ៖ដូចថាញ៉ុមថាចឹងដល់ខែយើងទៅបាត់ទៅណាស់!!!លក់វាមិនកើត ដល់ញ៉ុមទៅបាត់កូនអត់តំណាងកើតដូចថាវាធ្វើមិនកើតតែម្ដងកូនញ៉ុមវាឃឹតហើយនំបញ្ចុកវានឿយណាស់!!!ក៖ចាំ!!ខ៖នឿយយើងក្រោកឡើងស្លទឹកនំអីម៉ោង៣យើងក្រោកបាត់ហើយតែកូនញ៉ុមអត់ធ្វើអត់កើតទេញ៉ុមអត់ដែលបង្ហាត់តាំងពីរតូចមកផងតែម្ដង។ក៖ចាំ!!ខ៖កូនដេកក្រោកស្ទើរម៉ានក្រោកទៅញ៉ុមអត់ចេះ អត់ចេះប្រើកូនបើខែស្រែកូនញ៉ុមថាម៉ោង៥ហើយ ម៉ោង៥ភ្លឺព្រៀងៗណាស់ ដាស់កូនអោយទៅកំពុងអាពេញដេកលក់វាស្រណោះកូនណាស់!!!។ក៖ចាំ!!!ខ៖ដាស់កូនអោយទៅ ព្យួរកូនអើយភ្លឺហើយទៅព្យួរទៅកូន ដល់យើងនៅឯណោះ ម៉ែនៅនេះនោះ បាទ បាទដេកលក់វិញសូន្យអត់ហ៊ានដាស់កូនទេ ប៉ុននេះកូនអញកំពុងតែដេកលក់ នឹកឃើញអញ្ចេះណាស់ នឹកឃើញចឹងក៏អត់បន្តិចទៀតទៅ អត់អត់ទាល់តែភ្លឺច្បាស់បានដាស់ទៀតហ៎ា ដាស់ទៅបានក្រោកទៅចេះឯងញ៉ុមអត់សូវដែលចេះប្រើកូនទេ កូនញ៉ុមទាំងអស់ញ៉ុមអត់សូវដែរចេះប្រើទេ ធ្វើអីញ៉ុមធ្វើតែខ្លួនឯងតែម្ដង។

ក៖ចឹងមីងអត់ធ្វើមួយហ្នឹងបានដោយសារត្រូវធ្វើស្រែចឹងទៅហេ៎?

ខ៖ចាំ។

ក៖ធ្វើស្រែទៅស្រុកឆ្ងាយៗចឹងទៅ។

ខ៖ចាំ!!នៅឆ្ងាយ។

ក៖ហើយចុះនៅនេះមានដីទំនេរមានធ្វើទេ?

ខ៖ដីនៅទីនេះអោយប្អូនធ្វើ។ក៖ចាំ!!ខ៖ស្រែមាន២ ៣នោះឯងមិនមានច្រើនទេ ស្រែវាលយើងនេះ។

ក៖ហើយចុះបើស្រែវាលនៅណោះស្រែប៉ុន្មាន?

ខ៖ឯណោះស្រែមិនមែនស្រែយើងទេ ដូចថាយើងទៅសុំដីគេធ្វើតែម្ដង។ក៖ចាំ!!ខ៖ដីព្រៃទៅគេអោយយើងកាប់ធ្វើចំការស្រលះទៅដាំស្រូវហូបហ្នឹង ដល់ពេលស្រលះហ្នឹងគេយកយើងតែដីគេយើងធ្វើតែមួយស្រូវហូបនោះឯង។

ក៖ចាំ!!ហើយមានអោយស្រូវទៅគេខ្លះទេមីង?

ខះអត់ទេ   អត់យកស្រូវទេគេអោយយើងធ្វើភោគផលយកមកផ្ទះបានប៉ុណ្ណាប៉ុនទៅគេមិនយកទេ។

កះគេចិត្តល្អ។

ខះចាំគេអោយតែស្រលះដីគេទៅណាស់!!!

កះចាំល្អមែនទែន គេមួយជីវិតញ៉ុមនេះគេអោយធ្វើមួយជីវិតក៏បានដែរ។

កះមីងអត់ខ្លាចនឿយម៉ងហ៎ា!!!

ខះអត់ខ្លាចនឿយទេញ៉ូមមួយជីវិតនេះញ៉ុមអត់ខ្លាចនឿយតែម្តង។

កះហ្នឹងហើយ។

ខះកុំអីញ៉ុមមិនដែលចាស់អីប៉ុននេះទេ   ញ៉ុមនិយាយត្រង់   ញ៉ុមនឿយណាស់   ចាំខែធ្វើចំការធ្វើស្រែញ៉ុមខំទៅទាំងកំលាំងទេ      អត់ជួលគេទេ។កះចាំ!!ខះដូចទៅថាខែភោគផលបើញ៉ុមមានលុយញ៉ុមជួលគេធ្វើអត់ទាន់ចាំ!!

កះហ្នឹងហើយ។

ខះបើថាខែធ្វើវិញងាប់រស់។

កះដឹងថាបានមកច្រើនហេ?

ខះចាំ។កះចឹងមីងបើសិនជាចង់លក់មាន់អាំងអីចឹងអោយកូនចិញ្ចឹមមាន់អោយច្រើនទៅ!!!

ខះអានោះរឿងរបស់គេ។

កះហើយមីងមានចិញ្ចឹមមាន់ទេនៅផ្ទះ?

ខះញ៉ុមចិញ្ចឹមអត់ដែលកើតទេ   កូនចិញ្ចឹមដែរ   ប៉ុន្តែតែដល់ខែឈឺងាប់អស់រលីង   ចាំចិញ្ចឹមមិនដែលកើតទេ។

កះចិញ្ចឹមអាខែអត់ឈឺទៅអត់!!!

ខះដូចថាអាខែអត់ឈឺ ចេះវាកំពុងកើតណាស់!!កះចាំ!!ខះវាកំពុងកើតធំមួយល្មម កំពុងតែមានយើងជិតបានលក់បានអីអញ្ចេះ   ដល់ពេលវាឈឺក៏ឈឺងាប់អស់រលីង   ចាំងាប់សឹងតែមិនសល់ពូជទៅណា!!វាងាប់អស់ចេះឯង។កះចាំ!!ខះចិញ្ចឹមអត់ដែលចេះនៅដូចថាយើងចិញ្ចឹមអញ្ចេះឯងតាមជម្មជាតិណាស់!!

កះហ្នឹងហើយ។

ខះមិនដែលបានប្រើថ្នាំប្រើអីនឹងគេទេណាស់!!ចាំ!!

ក៖ពេលចិញ្ចឹមងាប់អស់រលីងចឹងទៅ!!ចឹងមីងរាល់ថ្ងៃធ្វើស្រែចំការមីងណោះ?

ខ៖ចាំធ្វើស្រែ។

ក៖ចឹងមីងសំរាប់ស្វាមី?

ខ៖ប្តីញ៉ុមធ្វើតែស្រែមកវិញនៅផ្ទះអត់ដែលបានរកអីទេ៧ឆ្នាំហើយ វះ!!!

ក៖វះអីគេវិញ?

ខ៖វះគាត់បួសថ្លើមហ៉ា!!!ទៅគាត់អត់ដែលរកអីទេសព្វថ្ងៃខ្ជិលណាស់អោយតែនៅផ្ទះបានហើយទៅធ្វើចំការអញ្ចេះបានទៅដែរ ទៅដូចថាទៅធ្វើវាអត់បានពេញកំលាំងណាស់!!ក៖ចាំ!!ខ៖គាត់អត់កំលាំង គាត់ទៅអោយតែមានតែទៅជាមួយគ្នាណាស់!!

ក៖ហ្នឹងហើយ។

ខ៖បើថាយកធ្វើយកពេញកំលាំងនោះទៅមិនរួចទេ!!ក៖ចាំ!!ខ៖ដូចថាយើងទៅជើងមុនក៏ដោយជើងក្រោយក៏ដោយ ដើរជើងមុនទៅផ្សំៗនឹងគេអញ្ចេះឯងចាំ។

ក៖ចាំចឹងមីងមួយនេះគឺជាសំណួរមួយចុងក្រោយ អរគុណមែនទែនដែលអ្នកមីងបានរៀបរាប់បានក្បោះក្បាយបានពិរោះណាស់ ។ខ៖ចាំ!!ក៖ញ៉ុមស្រលាញ់ចូលចិត្តមួយហ្នឹងអើមីងមានដំបូន្មានឬក៏បទពិសោធន៍អ្វីដែលល្អនៅក្នុងជីវិតហ៉ាដែលចង់ចែកចាយហើយផ្តាំផ្ញើកូនចៅជំនាន់ក្រោយហើយឬក៏អ្វីដែលចង់មានបញ្ចេញអារម្មណ៍ទៀតសូមប្រាប់មកទាំងអស់ចង់វែងប៉ុន្នានក៏បានដែរ?

ខ៖ញ៉ុមមានពាក្យអីអត់សូវចេះនិយាយ។

ក៖បទពិសោធន៍អីគេខ្លះចឹងហ៉ា!!!ដែលល្អនៅក្នុងជីវិតចឹងហ៉ា?

ខ៖បើយើងល្ងង់ដែរដឹង!!

ក៖ដូចជាការធ្វើការរកស៊ីឬក៏ធ្វើការទូន្មានមកពីដូនតាចឹងណាមីង។

ខ៖ញ៉ុមអត់ដឹងថាក្នុងគិតចិត្តគិតថារម៉េច!!

ក៖ដូចថាតឡូវដូចជាដំបូន្មានចង់ផ្តាំផ្ញើរគាត់យ៉ាងម៉េចដែរ?

ខ៖បើក្នុងជីវិតញ៉ុមរាល់ថ្ងៃដែលផ្តាំកូនមានតែថាប្រដៅអោយកូនណែនាំអោយរកស៊ីទៅមុខអោយគេរកអីបានអោយយើងរកនោះនឹងគេទៅណាកូន។ក៖ចាំ!!!!ខ៖មានតែអញ្ចុះឯងញ៉ុមបើថាចិត្តញ៉ុមរាល់ថ្ងៃនឹកឃើញប៉ុននេះហើយអោយតែកូនមានមុខរបររកស៊ីនឹងគេចុះ ខ្លួនឯងនឹកឃើញថាគេចុះបានមួយពេលស៊ីមួយពេលទៅ។ក៖ចាំ!!ខ៖ចាំ!!!

ក៖ចឹងមីងដល់ពេលឈឺថ្កាត់ទៅម៉េចវិញទៅមីង?

ខ៖ចុះបើឈឺថ្កាត់ម៉េចបើយើមមើលមិនឃើញ។

ក៖អូ!!ញ៉ុមភ្លេចមួយទៀតដោយសារអ្នកមីងនៅក្នុងតំបន់អង្គរហ្នឹងតើអ្នកមីងមានអារម្មណ៍ម៉េច
ដែរនៅពេលដែលនៅតំបន់អង្គរមានភ្ញៀវមកលេងហើយនឹងមានទឹកដីដូចជាដូនតាយើងបាន
បន្សល់អោយចឹងហ៉ាមីងមានអារម្មណ៍ម៉េចដែរ?

ខ៖មានអារម្មណ៍ថាសប្បាយ។

ក៖សប្បាយចិត្តហេ?

ខ៖ចុះបើមិនថានេះទេទោះបីយើងទៅស្រុកគេទីណាអត់ដូចទឹកដីយើងទេ ញ៉ុមណាស់ នឹកឃើញទឹកដីយើងចូលមកត្រជាក់ស្រើប ទឹកដីអង្គរនេះម៉ាឆ្វៃលជុំវិញអង្គរនេះគឺត្រជាក់មែនណាស់!! ចាំដូចថាយើងចេញពីអង្គរទៅសុទ្ធតែក្តៅរហូតចូលដល់ទឹកដីអង្គរយើងត្រជាក់។ក៖ចាំ!!ខ៖ចាំ!ដូចសប្បាយ។

ក៖ហ្នឹងហើយមានព្រៃមានអីចឹងទៅមីងណោះ?

ខ៖ចាំទោះបីទៅស្រុកគេសំបូរសប្បាយដែរប៉ុន្តែមិនដូចស្រុកយើងចាំ!!ក៖ចាំ!!ខ៖ស្រុកយើង ទោះបីតែយើងអត់ យើងទៅរកស៊ីស្រុកគេមែនប៉ុន្តែថាជីវភាពក្រុមគ្រួសារយើងចិត្តយើងនៅតែឯណោះ។

ក៖ចាំមិនអាចបោះបង់ទឹកដីកំណើតបានអ្នកមីងហ្នឹង?

ខ៖ចាំទៅនៅឯណាក៏នឹកមកតែទីនេះ។

ក៖ចឹងមីងរាល់ថ្ងៃលក់នំចេកហ្នឹងជនជាតិបរទេសផ្សេងពីខ្មែរយើងគេទិញញ៉ាំអត់?

ខ៖អត់ អត់ដែលហូបទេ។

ក៖អត់ដែលគេអត់ធ្លាប់អ្នកមីង គេអត់ស្គាល់អ្នកមីងហេ?

ខ៖ចាំ!!!ដូចអត់ធ្លាប់។បើអាខ្លះវាធ្លាប់ក៏វាហូប។

ក៖ចាំ!!ចឹងភាគច្រើនមានតែជនជាតិខ្មែរយើងពិសារ។

ខ៖មានតែខ្មែរយើងពិសារព្រោះអីនំញ៉ុមតែខ្មែរគ្នាយើងដូចថាស្គាល់គ្នាអញ្ចេះក៏ទៅទីណាក៏គេហូបដែរ បើអ្នកដូចអត់សូវហូបអញ្ចេះគេអត់ហូប បើខ្លះគេទិញបានហូបតែម្តងទៅគេដឹងថ្ងៃក្រោយយើងមិនពិបាកហៅទេគេហៅយើងវិញចាំ!!!

ក៖ចាំហ្នឹងហើយចឹងវាចឹង ចឹងមីងលក់ដាច់រាល់ថ្ងៃអស់ម៉ងមីងហេ?

ខ៖រាល់តែថ្ងៃ។

ក៖ហើយចឹងនៅតំបន់អង្គរហ្នឹងមីងមានដែលទៅរកត្រីអីនៅជុំវិញអង្គរនឹងទេ?

ខ៖អត់ទេសព្វថ្ងៃញ៉ុមអត់ដែលរកទេ ប្តីខ្ញុំពីក្មេងមករក ។

ក៖ចាំ!!រក។

ខ៖ចាំរកតែត្រពាំងយើងកាសិនហ្នឹង។ក៖ចាំ!!ខ៖ដល់ពេលគេចូលអាសម័យអប្បរាប្តីញ៉ុមឈប់រហូត។ក៖ចាំ!!ខ៖មិនដែលរកទេគេតំបន់ណាគេហាមឃាត់ គេហាមឃាត់សម្បត្តិ សម្បត្តិតែនឹងព្រៃរកស៊ីត្រីសាច់ សម្បត្តិតែអុសប្តីញ៉ុមនឹង ហត់តែគេបិតផ្លិប ប្តីញ៉ុមឈប់ឡើងត្នោតរហូត។

ក៖ចាំ។ខ៖ប្តីញ៉ុមឡើងត្នោតរហូត។

ក៖ម៉េចវិញទៅមីងមីងអាចប្រាប់បន្តិចមើល?

ខ៖តាំងពីញ៉ុមបានប្តីញ៉ុមមក ប្តីញ៉ុមឡើងត្នោតរហូត តាំងពីញ៉ុមបានគាត់មកណាស់!!! តាំងពីរកូនមួយដល់កូន៥ ៦ ។

ក៖ចឹងមីងតើការឡើងត្នោតហ្នឹងគាត់ធ្វើអីគេខ្លះ?

ខ៖ញ៉ុមកូរតែស្ករទេ។

ក៖ធ្វើស្ករហេ៎?ខ៖ចាំ!!!ក៖ចុះមីង មីងអាចប្រាប់បន្តិចថារបៀបធ្វើស្ករហ្នឹងធ្វើម៉េចទៅ?

ខ៖រំងាស់ទឹកត្នោត។

ក៖មានដាក់អីផ្សេងទៀតទេ?

ខ៖ដាក់តែពពេល ពេលយើងធ្វើទឹកត្នោតបានយើងដាក់ពពេលក្នុងបំពុង។

ក៖អាពពេលហ្នឹងគេទៅ?

ខ៖ពពេលដើមឈើយើងហ្នឹង។ក៖ចាំ!!ខ៖ដល់ដាក់ទៅទឹកត្នោតយើងវាជាតិចត់ដូចឡាវណាស់!!!ចត់ ចត់ៗទៅវាថ្លាទឹកត្នោត វាថ្លាទៅវាផ្អែម។ក៖ចាំ!!ខ៖ពីមុនតែយើងឡើងយើងអបបំពង់អបបំពង់ជាមួយស្លឹកត្នោត។ក៖ចាំ!!!ខ៖អត់មានឡើងដូចគេសព្វថ្ងៃទេ។សព្វថ្ងៃគេដាក់តែអាកាដុងការហ្នឹង។ក៖ចាំ!!!ខ៖ញ៉ុម កាលញ៉ុមញ៉ុមសកបំពង់ឬស្សី។

ក៖អបបំពង់ហ្នឹងម៉េចទៅមីងញ៉ុមឆ្ងល់ដល់ហើយនេះ។

ខ៖អាយកស្លឹកត្នោតហ្នឹងដុតនឹងភ្លើងទៅ។ក៖ហ្ន៎!!!ខ៖ដុតនឹងភ្លើងទៅ យកទៅញ៉ុកអាក្នុងបំពង់ហ្នឹង ហើយយើងគាស់អាកាញមនោះចេញ។

ក៖ហ្នឹងហើយ។

ខ៖ដល់ពេលយើងត្រងទឹកត្នោតទៅស្រក់មកជាត់ល្ហុយប៉ា!!!ដល់ពេលយើងហូបទឹកត្នោតក៏ឆ្ងាញ់ដែរ ល្ហុយ ដល់ពេលសព្វថ្ងៃអត់ទេ ទឹកត្នោតគេសព្វថ្ងៃគេដាក់តែបំពុងការហ្នឹង។

ក៖ចាំហ្នឹងហើយឃើញ។

ខ៖ចាំអត់ឆ្ងាញ់ទេហើយទឹកត្នោតថ្លា ផ្អែមយ៉ាងណាក៏អត់ល្ហុយដែរ។

ក៖ចាំចឹងគាត់ឥឡូវគាត់លែងឡើងទៀតហើយមីងណោះ?

ខ៖ឡើងមិនកើតទេ។

ក៖ហើយពេលយកបានស្ករមកទៅលក់នៅក្នុងស្រុកហ្នឹងឬក៏ទៅលក់នៅស្រុកឆ្ងាយ?

ខ៖ប៉ះណាដែលញ៉ុមនៅក្មេងវិញគេមកយកតែនឹងផ្ទះចាំ ដល់ពេលដែលស្រុករើទៅ ញ៉ុមដឹកលក់ខ្លួនឯង។ក៖ចាំ!!ខ៖បាន ៤០ ៥០គីឡូញ៉ុមដឹកទៅម្ដង។

ក៖ចាំប៉ុន្មានថ្ងៃបាន បាន៣០ ៤០គីឡូមីង?

ខ៖៣ ថ្ងៃ ២ថ្ងៃហ្នំបានច្រើនដែរ។

ក៖បាន១គីឡូប៉ុន្មានដែរជំនាន់ហ្នឹង?

ខ៖៦០០។

ក៖ហើយធម្មជាតិបានតែ៦០០ទេ?

ខ៖៦០០ខ្មែរយើងសព្វថ្ងៃ។សព្វថ្ងៃបាន៦ ៧០០០។ក៖ចាំ!!ខ៖ដល់ម៉ឺន បើស្ករផែនបាន៧ ៨០០០ ១០០០០ក៏មានលក់អោយជនជាតិមានតែម៉ឺន បើញ៉ុមកាលនោះ១គីឡូ៦០០ ៧០០បានថ្លៃហើយ ៥០០ បើអាស្ករផែនយើងបានយី៦០០ ៥០០ទឹមបានអា៩០ប៉ុន្មាននេះទេ!! អាឡើងមុនដំបូងនោះបានតែ១គីឡូ៥រៀលហ្នឹង ស្ករផែនបាន២០រៀល។ក៖ចាំ!!ខ៖អាលុយខ្មែរកាលនោះណាស់!!បានតែ២០រៀល ៥រៀល។

ក៖ជំនាន់នោះគេប្រើកាក់មីងនោះ។

ខ៖ចាំប្រើកាក់ហ្នឹង។ក៖ចាំ!!ខ៖បាន២០រៀលហ្នឹង។

ក៖ហ្នឹងហើយ។

ខ៖១គីឡូអាស្កររឹងទេណាស់!!បាន២០រៀល។

ក៖ចឹងរកមុខឃើញហើយអ្នកលក់ស្ករត្នោត។

ខ៖យីដូចថាកូនញ៉ុម កូនញ៉ុមទៅញ៉ុមទៅមិនរួចដូចញ៉ុមទេ ព្រឹកឡើងញ៉ុមទៅលក់ស្ករកូន៣ណាស់ញ៉ុមប្រាប់ កូន៣អាបងទុកនៅផ្ទះអាមួយអោបឡាំងស្ករអាមួយជិះពីមុខ ចាំដាក់ឡាំងនៅឯក្រោយ ជិះអោបឡាំងស្ករទប់ពីក្រោយចាំទៅ ឌុបស្ករទៅ ថាអើដូចនៅផ្ទះប៉ុន្មានទៀតកុហកគេនៅផ្ទះ២ ៣។

ក៖ចាំកូនច្រើនបណ្ដាក់ៗគ្នាម៉ងមីងហេ?

ខ៖ចាំ!!!

ក៖ប៉ុន្មានឆ្នាំមួយ?

ខ៖៣ ២ ។៤ ២។ចាំដឹកស្ករលក់ បើដល់ពេលញុំមកូនធំគ្រាន់ទៅទុកអោយវានៅនឹងផ្ទះទៅ។

ក៖ចាំហ្នឹងហើយ បងទៅរៀនអញ្ចេះ មីនេះអីនៅផ្ទះអោយមើលប្អូនទៅ ។ក៖ចាំ។ខ៖បើអង្កាល់ទើបពាវិញទៅណារយោងអត់ដែលហ៊ានទុកកូនចោលទេ ជួនកាលក្រោកពីព្រលឹមឡើងចេះទៅលក់ស្ករ មកដល់ប្ដីឡើង យើងមកដល់ដងទឹកលាងបំពង់ដុតភ្លើង គេចុះពីចុងត្នោតទៅរកអុស។

ក៖ចាំសុទ្ធចែកការងារគ្នាដាច់។

ខ៖ចាំសុទ្ធចែកការងារ គេមកដល់បើស្ករខាស់អញ្ចេះ គេកូរស្កររួចគេទៅដឹកអុសមួយជើងទៀ ត ចុះពីចុងត្នោតទៅដឹកម្ដងទៀត ដឹកកង់ហា!!!

ក៖ចុះមីងរំងាស់ហ្នឹង ពីស្ទើរម៉ាន់ដល់ស្ទើរម៉ានបានចេញជាស្ករ?

ខ៖រំងាស់ បើយើងឆាប់បានរំងាស់ម៉ោងមួយអីខាស់ហើយ។

ក៖ហ្ហំហើយកូររហូតម៉ងហេ?

ខ៖អត់ទេយើងរំងាស់ដល់កើតស្ករបានកូរ។ក៖ហ្ហំហ្ហំ!!!ខ៖ចេះតែដុតភ្លើងទៅណាស់!!!

ក៖ហ្នឹងហើយយល់ហើយ។

ខ៖ដុតឃើញថាវាឡើងស្ករ ដូចនំកូរ វាឡើងដូចនំកូរយើង យើងលើក លើកមកកូរ។ក៖ចាំ!!ខ៖អាហ្នឹងបានកើតស្ករ។

ក៖ហ្នឹងហើយ។

ខ៖បើថាយើងលើកមកអត់កូរអត់កើតដែរ។ក៖ចាំ!!ខ៖វារាំវកខ្លួកហ្នឹងដដែល។

ក៖ហ្នឹងហើយដល់កូរបានខាប់។

ខ៖ចាំ ដល់កូរបានខាប់។

ក៖ចាំ ហ្នឹងហើយ។

ខ៖បើយើងធ្វើរាំវវាទើបនឹងឡើងភុកៗតិចៗយើងឡើងមករាំវហើយណាស់ យើងកូររាំវណាស់! បើយើងចង់ទុកអោយខាប់បន្តិចយើងទុកអោយដូចនំកូរ។ក៖ចាំ!!ខ៖ទាល់តែពេលភុកមក លើកមកកូរទៅខាប់។

ក៖ឆ្ងាញ់ខ្លាំងណាស់មីងហេពេលហ្នឹង?

ខ៖ផ្អែមហើយឈ្ងុយទៀត។

ក៖ចាំ!!ហិតក្លិនរហូតកូន។

ខៈហ្នឹងហើយ ហើយយើងធ្វើនំក៏ឆ្ងាញ់ដែរ ស្ករយើងធ្វើខ្លួនយើងណាស់!!!កៈចាំ!!ខៈវាឈ្ងុយ បើសព្វថ្ងៃនោះស្ករក៏មិនដែលឃើញឆ្ងាញ់ទេ។កៈចាំ!!!ខៈញ៉ាំមទិញស្ករគេហូបអត់ដែលឃើញ ឆ្ងាញ់អីទេ!!! គេអត់អប់បំពង់។

កៈចាំចឹងអរគុណមែនទែនអ្នកមីងសំរាប់ការអើសំភាសន៍នៅក្នុងថ្ងៃនេះ ហើយមីងមានអីដែល ចង់ផ្ដែផ្ដាំអីទៀតឬក៏មានអីនិយាយចុងក្រោយអត់?

ខៈលែងមានអីនិយាយហើយ។

កៈចឹងមានតែប៉ុណ្ណឹងទេមីងណោះ?ខៈចាំ!!កៈចឹងអរគុណច្រើនមែនទែនសំរាប់ការចូលរួមនៅ ក្នុងថ្ងៃនេះសូមជូនពរអ្នកមីងសុខសប្បាយមានសុខភាពល្អហើយកូនចៅអ្នកមីងនឹងបានស្ដាប់ ឮសំដីរបស់អ្នកមីងហ៎ា!!!មីងចាំអរគុណច្រើនអ្នកមីង។

ខៈចាំ។